**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

# សេចក្តីណែនាំបច្ចេកទេស

# ស្តីពី

# ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**ខែតុលា ឆ្នាំ២០១៣**

# មាតិកា

**ផ្នែកទី១** ........ 15

**គោលការណ៍នៃការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** ........ 15

**ផ្នែកទី២** ........ 16

**អ្នកពាក់ព័ន្ធក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** ........ 16

**ផ្នែកទី៣** ........ 18

**ដំណើរការរៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** ........ 18

១. ជំហានទី១៖ ការរៀបចំ និងការផ្សព្វផ្សាយព័ត៌មានស្តីពីដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ........ 19

**១.១ ការរៀបចំឯកសារ និងព័ត៌មាន** ........ 19

**១.២ កិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** ........ 22

២.ជំហានទី២ ៖ ការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ........ 23

**២.១ កិច្ចប្រជុំវិភាគស្ថានភាព និងការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត** ........ 23

**២.២ ការពិនិត្យ កែសម្រួល និងអនុម័តក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត** ........ 24

**២.៣ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** ........ 25

**២.៤ ការរៀបចំក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** ........ 25

**២.៥ ការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** ........ 26

**២.៦ កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** ........ 27

**២.៧ ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** ........ 27

**២.៨ ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសលើសេចក្តីព្រាងផែនការ** 28

**អភិវឌ្ឍន៍រាជធានី ខេត្ត** ........ 28

៣.ជំហានទី៣ ៖ ការអនុម័ត និងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ........ 29

**៣.១ ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** ........ 29

**៣.២ ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** ........ 31

ផ្នែកទី៤ ........ 32
ទម្រង់សៀវភៅនិងសេចក្តីពន្យល់ពីខ្លឹមសារសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ........ 32
៤.១ ទម្រង់សៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ........ 32
៤.២ សេចក្តីពន្យល់ពីខ្លឹមសារសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ........ 33

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ និងក្រសួងផែនការ**

លេខៈ ៣៥១៤......ប្រក

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការកែសម្រួល ប្រការ ១ នៃប្រកាសអន្តរក្រសួងស្តីពីការកសាង ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញអនុក្រឹត្យលេខ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា ១២នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញប្រកាសអន្តរក្រសួងលេខ២៤១៧ ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងតាមស្មារតីនៃកិច្ចប្រជុំ គ.ជ.អ.ប លើកទី៨ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣

## សម្រេច

**ប្រការមួយ.**

កែសម្រួល ប្រការ ១ នៃប្រកាសអន្តរក្រសួងលេខ២៤១៧ ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចតទៅៈ

**ប្រការ ១ថ្មី.**

ប្រកាសនេះ មានគោលបំណងណែនាំក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការកសាង អនុម័ត និងអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលសម្រាប់រដ្ឋបាលរបស់ខ្លួន ដោយមានការចូលរួម និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមខ្លឹមសារនៃសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានកែសម្រួលឡើងវិញនាខែតុលា ឆ្នាំ២០១៣។

**ប្រការពីរ.**

ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **ទេសរដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងផែនការ** |
| ស ខេង | ឆាយ ថន |

<u>កន្លែងទទួល</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *សមាជិក គ.ជ.អ.ប*
- *ក្រសួង ស្ថាប័នពាក់ព័ន្ធ* *"ដើម្បីជូនជ្រាប"*
- *សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់* *"ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ និងក្រសួងផែនការ**
លេខ ៤៤១៧ ប្រក

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការរៀបចំផែនការអភិវឌ្ឍន៍
# និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

********

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- យោងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈ អភិបាលស្រុក
- យោងអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- យោងអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា១២នៃអនុក្រឹត្យ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងតាមការសម្រេចនៃកិច្ចប្រជុំ គ.ជ.អ.ប លើកទី៥ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងណែនាំក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការកសាង អនុម័ត និង អនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលសម្រាប់រដ្ឋបាលរបស់ខ្លួន ដោយមានការចូលរួម និងពិគ្រោះយោបល់ ជាមួយអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមខ្លឹមសារនៃសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាង ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្រោមសុពលភាពនៃប្រកាសអន្តរក្រសួង នេះ ។

**ប្រការ ២.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(០៥)ឆ្នាំ យ៉ាងយូរបំផុត នៅក្នុងឆ្នាំទី២នៃអាណត្តិរបស់ខ្លួន។ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាឯកសារយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងជាមូលដ្ឋានសម្រាប់រៀបចំកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលនឹងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

**ប្រការ ៣.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធានាឱ្យបានថា ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ កម្មវិធីវិនិយោគ បីឆ្នាំរំកិល ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ត្រូវបានដាក់បញ្ចូលនូវផែនការអភិវឌ្ឍន៍ និងថវិការបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធនានា ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។

**ប្រការ ៤.-**

ផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ត្រូវបញ្ចូលនូវផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំ រំកិលខណ្ឌ និងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគសង្កាត់នានាក្នុងដែនសមត្ថកិច្ចរបស់រាជធានី។

ផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ត្រូវបញ្ចូលនូវផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគសង្កាត់ នានាក្នុងដែនសមត្ថកិច្ចរបស់ក្រុង។

**ប្រការ ៥.-**

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាឯកសារផ្លូវការ ហើយក្រុមប្រឹក្សានីមួយៗត្រូវរៀបចំចាត់ចែងផ្សព្វផ្សាយឯកសារនេះជាសាធារណៈ និងជាបន្ទាន់នៅក្នុង ដែនសមត្ថកិច្ចរបស់ខ្លួន។

## ជំពូកទី២

## យន្តការ និងភារកិច្ចក្នុងការកសាងនិងអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**ប្រការ ៦.-**

ដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ស្ថិតក្រោមការដឹកនាំ និងត្រួតពិនិត្យរួមរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ភារកិច្ចសំខាន់ៗរបស់ក្រុមប្រឹក្សារួមមាន :

- ត្រួតពិនិត្យ និងចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ណែនាំផ្នែកគោលនយោបាយសម្រាប់ដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យ និងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យ និងអនុម័តសំណើកែតម្រូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- តាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំលើការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**ប្រការ ៧.-**

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- សម្របសម្រួលការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ក្រៅពីភារកិច្ចខាងលើ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល មុននឹងក្រុមប្រឹក្សាធ្វើការពិនិត្យ និងអនុម័ត។

**ប្រការ ៨.-**

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ដឹកនាំ និងសម្របសម្រួលការងារកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ស្របតាមការណែនាំរបស់ក្រុមប្រឹក្សា ដោយសហការជាមួយភាគីពាក់ព័ន្ធនានា
- ដឹកនាំសិក្ខាសាលា និងវេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**ប្រការ ៩.-**

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុមការងារកសាងផែនការរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា
- រៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ដឹកនាំ និងសម្របសម្រួលដំណើរការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រៀបចំសិក្ខាសាលា និងវេទិកាពិគ្រោះយោបល់នានាជាមួយភាគីពាក់ព័ន្ធនានា ក្នុងដំណើរការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**ប្រការ ១០.-**

ក្នុងដំណើរការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ទីចាត់ការ និងការិយាល័យនានា នៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ជួយក្រុមប្រឹក្សា និងគណៈអភិបាលក្នុងការដឹកនាំ និងសម្របសម្រួលដំណើរការកសាង អនុម័ត តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- សហការជាមួយក្រុមការងារកសាងផែនការក្នុងការដឹកនាំ និងសម្របសម្រួលការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ចូលរួមវិភាគស្ថានភាពនិងពិគ្រោះយោបល់ក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- សម្របសម្រួល និងចូលរួមការបណ្តុះបណ្តាលអំពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ។

## ជំពូកទី៣

## ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ប្រការ ១១.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន តាមរយៈដំណើរការដែលមានការចូលរួមនិងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ប្រភេទក្រុមប្រឹក្សាផ្សេងទៀត សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាពពាក់ព័ន្ធ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ដើម្បីរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រកបដោយគុណភាព និងស្របតាមគោលការណ៍ ដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យលេខ២១៩ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយ និងប្រតិទិនស្តីពីដំណើរការកសាងផែនការឱ្យបានច្បាស់លាស់ ដោយផ្អែកលើតម្រូវការជាអាទិភាពរបស់មូលដ្ឋាន សក្តានុពលរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយរបស់ជាតិ ។

គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា ត្រូវរៀបចំតាមរយៈដីកា ឬសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា។

ការចំណាយនានាសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល គឺត្រូវរ៉ាប់រងដោយថវិការបស់ក្រុមប្រឹក្សានីមួយៗ។

**ប្រការ ១២.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់ខ្លួន ដោយបញ្ចូលនូវខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- **ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ៖** រៀបរាប់ដោយសង្ខេបអំពីព័ត៌មានក្នុងស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច ការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ការគ្រប់គ្រងគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ និងស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល
- **ក្របខ័ណ្ឌអភិវឌ្ឍន៍ ៖** រៀបរាប់ពីចក្ខុវិស័យ គោលដៅ គោលបំណង និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនៃផែនការអភិវឌ្ឍន៍
- **ការតាមដាននិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ ៖** រៀបរាប់អំពីអ្នកទទួលខុសត្រូវនិងអ្នកចូលរួមក្នុងការវាយតម្លៃ វិធីសាស្ត្រវាយតម្លៃ និងការរៀបចំរបាយការណ៍។

**ប្រការ ១៣.-**

ក្នុងការកសាងផែនការអភិវឌ្ឍន៍ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវយកចិត្តទុកដាក់លើសកម្មភាពសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍
- ការផ្សព្វផ្សាយពត៌មានអំពីដំណើរការ និងនីតិវិធីសម្រាប់ការកសាងផែនការអភិវឌ្ឍន៍
- ការកសាងផែនការអភិវឌ្ឍន៍ តាមរយៈការវិភាគស្ថានភាព និងការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍ និង
- ការអនុម័តផែនការអភិវឌ្ឍន៍

**ប្រការ ១៤.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ដោយបញ្ចូលនូវខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- **ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ៖** រៀបរាប់ដោយសង្ខេបអំពីព័ត៌មានសេដ្ឋកិច្ច សង្គមកិច្ច ក្នុងស្ថានភាពបច្ចុប្បន្ន បញ្ហាប្រឈម និងតម្រូវការជាអាទិភាពរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- **គម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល ៖** រៀបរាប់អំពីគម្រោងវិនិយោគ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងផែនការសកម្មភាពសម្រាប់អនុវត្តគម្រោងឆ្នាំទី១នៃកម្មវិធីវិនិយោគបីឆ្នាំរំកិល។
- **ការតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ ៖** រៀបរាប់អំពីអ្នកទទួលខុសត្រូវ និងអ្នកចូលរួមក្នុងការវាយតម្លៃ វិធីសាស្ត្រវាយតម្លៃ និងការរៀបចំរបាយការណ៍។

**ប្រការ ១៥.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ដោយផ្អែកលើផែនការអភិវឌ្ឍន៍។ កម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ សកម្មភាពសំខាន់ៗនៃដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរួមមាន :

- ការវិភាគស្ថានភាព ដោយផ្ដោតលើការកំណត់បញ្ហា និងតម្រូវការជាអាទិភាព
- ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល

**ប្រការ ១៦.-**

ក្រសួងផែនការត្រូវជួយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការរៀបចំព័ត៌មានស្ដីពីវឌ្ឍនភាព នៃការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា កម្រងឯកសារស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងទិន្នន័យផ្សេងទៀតដែលពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**ប្រការ ១៧.-**

ក្រោយពេលដែលក្រុមប្រឹក្សារាជធានី ខេត្ត បានពិនិត្យ និងអនុម័តលើសេចក្ដីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្តរួចហើយ គណៈអភិបាលរាជធានី ខេត្តត្រូវធ្វើការកែសម្រួលដោយផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ហើយដាក់ជូនអភិបាលរាជធានី ខេត្តនូវសេចក្ដីព្រាងផែនការដែលបានកែសម្រួលនេះ ដើម្បីពិនិត្យ និងផ្ញើមកលេខាធិការដ្ឋាន គ.ជ.អ.ប។ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវធ្វើការថតចម្លងសេចក្ដីព្រាងនេះជូនក្រសួងមហាផ្ទៃ ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវធ្វើការសម្របសម្រួល ពិនិត្យ ពិគ្រោះយោបល់លើសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ជាមួយក្រសួងទាំងបីខាងលើនេះ ព្រមទាំងជាមួយស្ថាប័នពាក់ព័ន្ធនានា ដើម្បីពិនិត្យ និងផ្ដល់យោបល់លើភាពស្របច្បាប់ និងសង្គតិភាពនៃផែនការនេះជាមួយគោលនយោបាយជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ ក្រោយពេលពិនិត្យ និងពិគ្រោះយោបល់រួចរាល់ហើយ លេខាធិការដ្ឋានត្រូវធ្វើកំណត់បង្ហាញសុំយោបល់មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងផ្ដល់អនុលោមភាព។ ការពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ត្រូវធ្វើឡើងក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលទទួលបានការស្នើសុំពិនិត្យ និងផ្ដល់យោបល់របស់អភិបាលរាជធានី ខេត្ត។ រយៈពេល៣០ថ្ងៃនេះ រួមមានពេលវេលាចំណាយសម្រាប់ការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ការធ្វើទំនាក់ទំនងជាមួយអភិបាលរាជធានី ខេត្ត ដើម្បីស្រាយបំភ្លឺ និងឯកភាពលើយោបល់ដែលផ្ដល់ដោយក្រសួងមហាផ្ទៃលើសេចក្ដីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។

ក្នុងករណីមិនមានការឯកភាពគ្នារវាងអភិបាលរាជធានី ខេត្ត និងក្រសួងមហាផ្ទៃអំពីខ្លឹមសារសេចក្ដីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រសួងមហាផ្ទៃត្រូវរាយការណ៍ និងស្នើសុំ គ.ជ.អ.ប ដើម្បីធ្វើការសម្របសម្រួលដោះស្រាយ។

ក្នុងរយៈពេល៣០ថ្ងៃ បើគ្មានការឆ្លើយតបជាលាយល័ក្ខណ៍អក្សរពីក្រសួងមហាផ្ទៃផ្ញើទៅអភិបាលរាជធានី ខេត្តទេ នោះសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ត្រូវចាត់ទុកថាទទួលបានអនុលោមភាពពីក្រសួងមហាផ្ទៃ។

**ប្រការ ១៨..**

ក្រោយពេលដែលក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ បានពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌរួចហើយ គណៈអភិបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើការកែសម្រួលដោយផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ហើយដាក់ជូនអភិបាលក្រុង ស្រុក ខណ្ឌនូវសេចក្តីព្រាងផែនការដែលបានកែសម្រួលនេះ ដើម្បីពិនិត្យ និងផ្ញើជូនអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យ និងផ្តល់យោបល់លើភាពស្របច្បាប់ និងសង្គតិភាពនៃផែនការនេះជាមួយគោលនយោបាយជាតិ ច្បាប់ និងលិខិតបទដ្ឋាននានា។ អភិបាលរាជធានី ខេត្ត ត្រូវធ្វើការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលទទួលបានការស្នើសុំពិនិត្យ និងផ្តល់យោបល់ដោយអភិបាលក្រុង ស្រុក ខណ្ឌ ដោយសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធនានា។ រយៈពេល៣០ថ្ងៃនេះ រួមមានពេលវេលាចំណាយសម្រាប់ការធ្វើទំនាក់ទំនងរវាងអភិបាលក្រុង ស្រុក ខណ្ឌ ជាមួយនឹងអភិបាលរាជធានី ខេត្ត ដើម្បីស្រាយបំភ្លឺ និងឯកភាពលើយោបល់ដែលផ្តល់ដោយអភិបាលរាជធានី ខេត្ត លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ។

ក្នុងករណីមិនមានការឯកភាពគ្នារវាងអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលរាជធានី ខេត្ត អំពីខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្តត្រូវរាយការណ៍ និងស្នើសុំមកលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីធ្វើការសម្របសម្រួលដោះស្រាយ។

ក្នុងរយៈពេល៣០ថ្ងៃ បើគ្មានការឆ្លើយតបជាលាយល័ក្ខណ៍អក្សរពីអភិបាលរាជធានី ខេត្តទៅក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌទេ នោះសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ត្រូវចាត់ទុកថាទទួលបានអនុលោមភាពពីអភិបាលរាជធានី ខេត្ត។

ក្នុងការពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្ត ត្រូវពិចារណាអំពីភាពស្របច្បាប់ និងសង្គតិភាពនៃខ្លឹមសារផែនការអភិវឌ្ឍន៍ទៅនឹងគោលនយោបាយជាតិ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

**ប្រការ ១៩..**

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំបោះពុម្ព បែងចែក ផ្សព្វផ្សាយជាសាធារណៈនូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានអនុម័តដោយក្រុមប្រឹក្សា និងតម្កល់ទុកនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរផែនការរាជធានី ខេត្ត ការិយាល័យផែនការក្រុង ស្រុក ខណ្ឌ និងផ្ញើទៅក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធដទៃទៀត។

**ប្រការ ២០..**

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសំណើកែប្រែផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវតែអនុម័តដោយសម្លេងលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងមូល។

ក្នុងករណីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរំសាយមុនអាណត្តិ យោងតាមមាត្រា២៤ នៃច្បាប់

ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌថ្មី អាចទទួលយកផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលកំពុងមានទាំងស្រុង ឬអាចរៀបចំកែសម្រួលផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនោះ សម្រាប់រយៈពេលអាណត្តិដែលនៅសល់ ។

## ជំពូកទី៤

## ការអនុវត្តផែនការអភិវឌ្ឍន៍
## និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ប្រការ ២១.-**

បន្ទាប់ពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលត្រូវបានអនុម័ត ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការណែនាំឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចាត់ចែងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយមានតម្លាភាព មានគណនេយ្យភាព មានការចូលរួម និងមានប្រសិទ្ធភាព ។

**ប្រការ ២២.-**

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តគម្រោង និងសកម្មភាពនានានៃផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដូចជាការធ្វើលទ្ធកម្មការងារសាងសង់ សម្ភារៈ ឬទំនិញ និងសេវាកម្មជាដើម ។ល ។

## ជំពូកទី៥

## ការតាមដាន ការវាយតម្លៃ និងរបាយការណ៍

**ប្រការ ២៣.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការណែនាំឱ្យអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ធ្វើការតាមដាននិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយរួមទាំងគម្រោងនិង សកម្មភាពនានាដែលអនុវត្ត និងគ្រប់គ្រងក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាដោយ :

- ប្រភេទក្រុមប្រឹក្សាដូចគ្នា
- ប្រភេទក្រុមប្រឹក្សាផ្សេងទៀត
- មន្ទីរ អង្គភាពនានា
- អ្នកពាក់ព័ន្ធផ្សេងទៀតដូចជា អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា ។

**ប្រការ ២៤.-**

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការវាយតម្លៃអំពីលទ្ធផល និងសមិទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលជារៀងរាល់ឆ្នាំ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ។

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការវាយតម្លៃអំពីលទ្ធផល សមិទ្ធផល និងផលប៉ះពាល់នៃការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេល០៦ខែចុងក្រោយនៃអាណត្តិរបស់ក្រុមប្រឹក្សា ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ។

នីតិវិធីនៃការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមសេចក្ដីណែនាំរបស់ គ.ជ.អ.ប ។

**ប្រការ ២៥.-**

នៅចុងឆ្នាំនីមួយៗ គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំស្ដីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។ ខ្លឹមសាររបាយការណ៍នេះរួមមាន :

- វឌ្ឍនភាពការងារអនុវត្តក្នុងឆ្នាំកន្លងមក
- ទិសដៅការងារសម្រាប់អនុវត្តឆ្នាំខាងមុខ
- សេចក្ដីសន្និដ្ឋានរួម ។

ក្រៅពីរបាយការណ៍ប្រចាំឆ្នាំស្ដីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរបាយការណ៍ផ្សេងទៀត ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាជាប្រចាំ។

**ប្រការ ២៦.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុម័តរបាយការណ៍ប្រចាំឆ្នាំស្ដីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល និងរបាយការណ៍ស្ដីពីលទ្ធផលនៃការតាមដាន និងវាយតម្លៃ មិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ។

របាយការណ៍ប្រចាំឆ្នាំរបស់រាជធានី ខេត្ត ត្រូវផ្ញើជូនគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធនានា។

របាយការណ៍ប្រចាំឆ្នាំរបស់ក្រុង ស្រុក ខណ្ឌ ត្រូវផ្ញើជូនអភិបាលរាជធានី ខេត្ត គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធនានា។

របាយការណ៍ប្រចាំឆ្នាំដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវតម្កល់ទុកនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរ ការិយាល័យផែនការរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៦

## ការរៀបចំ និងការផ្សព្វផ្សាយសេចក្ដីណែនាំស្ដីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ប្រការ ២៧.-**

ក្រសួងផែនការ និងជាប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប ត្រូវសហការជាមួយក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំផ្សព្វផ្សាយ និងណែនាំឱ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនេះ ស្របតាមខ្លឹមសារនិងសកម្មភាពសំខាន់ៗដូចមានចែងក្នុងប្រការ១៣ ប្រការ១៤ ប្រការ១៥ និងប្រការ១៦នៃប្រកាសនេះ។

**ប្រការ ២៨.-**

ក្រសួងផែនការ និងជាប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប អាចធ្វើការកែសម្រួលសេចក្ដីណែនាំស្ដីពីការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមការចាំបាច់ បន្ទាប់ពីបានពិភាក្សាជាមួយក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប និងអ្នកពាក់ព័ន្ធផ្សេងទៀត ។

**ប្រការ ២៩.-**

ក្រសួងផែនការនិងជាប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប ត្រូវសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំឯកសារ កម្មវិធីផ្សព្វផ្សាយ និងការបណ្ដុះបណ្ដាលដល់អ្នកពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីនីតិវិធីកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចមានក្នុងសេចក្ដីណែនាំបច្ចេកទេសនេះ ។

## ជំពូកទី៧
## អវសានបញ្ញត្តិ

**ប្រការ ៣០.-**

ប្រកាសនេះ ពុំមានអធិកភាពលើប្រកាសអន្តរក្រសួងស្ដីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំសង្កាត់ឡើយ ប៉ុន្តែប្រកាសទាំងពីរមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ ជាពិសេសសម្រាប់សង្កាត់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរាជធានី និងសង្កាត់ស្ថិតក្នុងដែនសមត្ថកិច្ចក្រុង ។

**ប្រការ ៣១.-**

ប្រកាស និងសេចក្ដីណែនាំទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣២.-**

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី** **ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** **រដ្ឋមន្ត្រីក្រសួងផែនការ**

ស ៤២៦ នាយ ៩៨

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *សមាជិក "គ.ជ.អ.ប"*
- *ក្រសួង-ស្ថាប័នពាក់ព័ន្ធ*
  *"ដើម្បីជូនជ្រាប"*
- *សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់*
  *"ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*

# សេចក្តីណែនាំបច្ចេកទេស

# ស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

## សេចក្តីណែនាំបច្ចេកទេស
## ស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

សេចក្តីណែនាំបច្ចេទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ត្រូវបានរៀបចំកែសម្រួលឡើងវិញ ដោយផ្អែកលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យ និងប្រកាសអន្តរក្រសួងស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ផ្នែកទី១
## គោលការណ៍នៃការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

ការរៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ត្រូវផ្អែកលើគោលការណ៍សំខាន់ៗដូចខាងក្រោម ៖

១. ការចែករំលែកព័ត៌មាន
២. តម្លាភាព
៣. សង្គតិភាព និងសុខដុមនីយកម្ម
៤. ការចូលរួមពិគ្រោះយោបល់ជាទូទៅ
៥. ការឆ្លើយតបនឹងតម្រូវការ
៦. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
៧. ប្រសិទ្ធភាព និងសុក្រឹត្យភាពសេដ្ឋកិច្ច និងសង្គម
៨. ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន
៩. ការធានាសមធម៌

# ផ្នែកទី២
# អ្នកពាក់ព័ន្ធក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

## ២.១. ក្រុមប្រឹក្សារាជធានី ខេត្ត

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុមប្រឹក្សារាជធានី ខេត្តមានភារកិច្ចសំខាន់ៗ ដូចខាងក្រោម ៖

- ណែនាំផ្នែកគោលនយោបាយទូទៅសម្រាប់រៀបចំខ្លឹមសារផែនការអភិវឌ្ឍន៍
- ពិនិត្យ និងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍
- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍
- តាមដាន និងវាយតម្លៃក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍
- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍
- ពិនិត្យ និងអនុម័តសំណើកែតម្រូវផែនការអភិវឌ្ឍន៍ ក្នុងករណីចាំបាច់

## ២.២. គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និង គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានី ខេត្ត មានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍
- សម្របសម្រួលការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍
- ពិនិត្យ និងជូនយោបល់ទៅក្រុមប្រឹក្សា មុនធ្វើការអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ។

## ២.៣. គណៈអភិបាលរាជធានី ខេត្ត

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត គណៈអភិបាលរាជធានី ខេត្តក្នុងនាមក្រុមប្រឹក្សា មានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- ដឹកនាំ និងសម្របសម្រួលការងារកសាងផែនការអភិវឌ្ឍន៍ ស្របតាមការណែនាំពីក្រុមប្រឹក្សា ដោយសហការជាមួយភាគីពាក់ព័ន្ធនានា
- ដឹកនាំសិក្ខាសាលា វេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍
- ពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ មុនដាក់ជូនក្រុមប្រឹក្សាពិនិត្យ និង អនុម័ត
- ដាក់ជូនក្រុមប្រឹក្សា ពិនិត្យនិងអនុម័តផែនការអភិវឌ្ឍន៍
- តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ ។

## ២.៤. ក្រុមការងារកសាងផែនការរាជធានី ខេត្ត

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធី វិនិយោគរាជធានី ខេត្ត មានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា
- រៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍
- ដឹកនាំ និងសម្របសម្រួលដំណើរការកសាងផែនការអភិវឌ្ឍន៍

- រៀបចំសិក្ខាសាលា វេទិកាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនានាក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍
- រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ។

## ២.៥. ទីចាត់ការនានានៃសាលារាជធានី ខេត្ត

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ទីចាត់ការនានានៃសាលារាជធានីខេត្ត មានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- ជួយក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្តក្នុងការដឹកនាំ និងសម្របសម្រួលដំណើរការកសាង តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- សហការជាមួយក្រុមការងារកសាងផែនការរាជធានី ខេត្តក្នុងការដឹកនាំ និងសម្របសម្រួលការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ចូលរួមក្នុងការវិភាគស្ថានភាពរាជធានី ខេត្ត
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ។

## ២.៦. មន្ទីរ អង្គភាពនានា

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត មន្ទីរ អង្គភាពនានាក្នុងរាជធានី ខេត្តមានភារកិច្ចសំខាន់ៗ ដូចខាងក្រោម ៖

- ចូលរួម និងផ្តល់នូវព័ត៌មានពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍
- ចូលរួមក្នុងការវិភាគស្ថានភាពរាជធានី ខេត្ត
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ។

## ២.៧. ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវ ៖

- ចូលរួម និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ។

## ២.៨. ប្រជាពលរដ្ឋ

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ប្រជាពលរដ្ឋក្នុងរាជធានី ខេត្ត ត្រូវ ៖

- កំណត់បញ្ហា និងតម្រូវការអាទិភាពនានា តាមរយៈការចូលរួមក្នុងដំណើរការកសាងផែនការឃុំ សង្កាត់
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ចូលរួមក្នុងការតាមដាន និងវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍ ។

## ២.៩. អង្គការសង្គមស៊ីវិល និងវិស័យឯកជន

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត  អង្គការសង្គមស៊ីវិល  និងវិស័យឯកជននានាក្នុងរាជធានី ខេត្តត្រូវ ៖

- ចូលរួម និងផ្តល់នូវព័ត៌មាននានាដែលពាក់ព័ន្ធទៅនឹងការកសាងផែនការអភិវឌ្ឍន៍
- ចូលរួមក្នុងការវិភាគស្ថានភាពរាជធានី ខេត្ត
- ចូលរួមក្នុងការពិភាក្សា និងពិគ្រោះយោបល់នានាដែលពាក់ព័ន្ធនឹងដំណើរការកសាងផែនការអភិវឌ្ឍន៍។

# ផ្នែកទី៣

# ដំណើរការរៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

ក្រុមប្រឹក្សារាជធានី ខេត្តត្រូវធានាឱ្យបានថា ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ខ្លួន ត្រូវបានដាក់បញ្ចូលនូវផែនការអភិវឌ្ឍន៍របស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធនានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត។

ក្រុមប្រឹក្សារាជធានី ខេត្តជាអ្នកទទួលខុសត្រូវក្នុងការរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមរយៈកម្មវិធីវិនិយោគបីឆ្នាំរំកិល ។ ដូច្នេះ ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត គឺស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងដោយក្រុមប្រឹក្សារាជធានី ខេត្ត ។

ចំពោះផែនការអភិវឌ្ឍន៍រាជធានី ត្រូវបញ្ចូលនូវផែនការអភិវឌ្ឍន៍របស់ខណ្ឌ និងផែនការអភិវឌ្ឍន៍របស់ សង្កាត់ ដែលស្ថិត ក្នុង ដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី។

ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្តមាន ៣ជំហាន ៖

- ជំហានទី១ ៖ ការរៀបចំនិងការផ្សព្វផ្សាយព័ត៌មានស្តីពីដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានីខេត្ត
- ជំហានទី២ ៖ ការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ជំហានទី៣ ៖ ការអនុម័ត និងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

## ១. ជំហានទី១៖ ការរៀបចំ និងការផ្សព្វផ្សាយព័ត៌មានស្តីពីដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**ក) គោលបំណង**

- រៀបចំ និងផ្សព្វផ្សាយឯកសារ និងព័ត៌មានពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ដែលមានដូចជា ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត តារាងវិភាគស្ថានភាព គោលការណ៍ណែនាំ ផ្នែកគោលនយោបាយ ប្រតិទិនការងារ ទិន្នន័យ និងឯកសារពាក់ព័ន្ធដទៃទៀតសម្រាប់ការកសាង ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។

**ខ) លទ្ធផលរំពឹងទុក**

- តារាងវិភាគស្ថានភាពរៀបចំដោយអ្នកពាក់ព័ន្ធ
- តារាងបូកសរុបការវិភាគស្ថានភាព
- គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
- ប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ឯកសារពាក់ព័ន្ធផ្សេងៗដូចជា ឯកសារស្តីពីវឌ្ឍនភាពក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាថ្នាក់ក្រោមជាតិ ឯកសារព័ត៌មានស្ថានភាពរាជធានី ខេត្ត ដែលបានធ្វើបច្ចុប្បន្នភាពរួច និងទិន្នន័យតាមវិស័យ
- ការយល់ដឹងកាន់តែប្រសើរឡើងពីដំណើរការ និងកិច្ចការកសាងផែនការអភិវឌ្ឍន៍ក្នុងចំណោមអ្នកពាក់ព័ន្ធស្តីពី៖
  - តារាងបូកសរុបការវិភាគស្ថានភាព
  - គោលការណ៍ណែនាំផ្នែកគោលនយោបាយ និង
  - ប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ ។

**គ) ដំណើរការ**

ជំហានទី១ រួមមាន ២ សកម្មភាពដូចខាងក្រោម៖

១.១ ការរៀបចំឯកសារ និងព័ត៌មាន

១.២ កិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

### ១.១ ការរៀបចំឯកសារ និងព័ត៌មាន

**ក) លទ្ធផលរំពឹងទុក**

- តារាងវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ
- តារាងបូកសរុបការវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ
- គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
- ប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ឯកសារពាក់ព័ន្ធផ្សេងៗដូចជា ឯកសារស្តីពីវឌ្ឍនភាពក្នុងការអនុវត្តគាលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាថ្នាក់ក្រោមជាតិ ឯកសារព័ត៌មានស្ថានភាពរាជធានី ខេត្ត ដែលបានធ្វើបច្ចុប្បន្នភាពរួច និងទិន្នន័យតាមវិស័យ។

ខ) កិច្ចការដែលត្រូវធ្វើ

- ការរៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ការរៀបចំតារាងវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ
- ការរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
- ការរៀបចំបញ្ជីឯកសារពាក់ព័ន្ធនានា

### ១.១.១ ការរៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

ក) សមាសភាពចូលរួម

- ក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត

ខ) លទ្ធផលរំពឹងទុក

- ប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

គ) កិច្ចការដែលត្រូវធ្វើ

ប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ គឺជាផែនការសកម្មភាពមួយបង្ហាញពីសកម្មភាព ក្របខ័ណ្ឌពេលវេលា ទីកន្លែង អ្នកទទួលខុសត្រូវ និងធនធានដែលត្រូវការចាំបាច់ (តារាង ១.១៖ ទម្រង់គំរូប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត)

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត រៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ការកសាងផែនការអភិឌ្ឍន៍។
- ក្រុមការងារកសាងផែនការ ដាក់ជូនគណៈអភិបាលពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងប្រតិទិនការងារមុននឹងដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

### ១.១.២ ការរៀបចំតារាងវិភាគស្ថានភាពរាជធានី ខេត្ត

ក) សមាសភាពចូលរួម

- តំណាងក្រុមប្រឹក្សារាជធានី ខេត្ត និងតំណាងគណៈកម្មាធិការពាក់ព័ន្ធនានា
- តំណាងគណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត
- តំណាងគណៈអភិបាលក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្ត
- តំណាងមន្ទីរ អង្គភាពនានាក្នុងរាជធានី ខេត្ត
- តំណាងអង្គការសង្គមស៊ីវិលនានាក្នុងរាជធានី ខេត្ត
- តំណាងវិស័យឯកជនសំខាន់ៗក្នុងរាជធានី ខេត្ត
- អ្នកពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

ខ) លទ្ធផលរំពឹងទុក

- តារាងវិភាគស្ថានភាពរៀបចំដោយអ្នកពាក់ព័ន្ធ
- តារាងបូកសរុបការវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ

**គ) កិច្ចការដែលត្រូវធ្វើ**

ដើម្បីណែនាំស្ដីពីការរៀបចំតារាងវិភាគស្ថានភាព ដល់ក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាព អង្គការសង្គមស៊ីវិល និងវិស័យឯកជននានានៅក្នុងរាជធានី ខេត្ត៖

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត រៀបចំកិច្ចប្រជុំដល់អ្នកពាក់ព័ន្ធ ដើម្បីបំពេញតារាងវិភាគស្ថានភាព (តារាង ១.២៖តារាងវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ)។
- បន្ទាប់ពីទទួលបានតារាងវិភាគស្ថានភាពពីអ្នកពាក់ព័ន្ធ ក្រុមការងារកសាងផែនការ ត្រូវពិនិត្យ និងបូកសរុបចូលទៅក្នុងតារាងបូកសរុបការវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ (តារាង១.៣)។

### ១.១.៣ ការរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត

**ក) សមាសភាពចូលរួម**

- ក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត

**ខ) លទ្ធផលរំពឹងទុក**

- សេចក្ដីសម្រេចស្ដីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត

**គ) កិច្ចការដែលត្រូវធ្វើ**

គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាគឺជាឯកសារមូលដ្ឋានគន្លឹះសម្រាប់ណែនាំនិងតម្រង់ទិសក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត។ ឯកសារណែនាំផ្នែកគោលនយោបាយនេះត្រូវផ្អែកលើ៖

- តម្រូវការអាទិភាពនៅមូលដ្ឋាន ដោយផ្អែកទៅលើតារាងបូកសរុបការវិភាគស្ថានភាពរាជធានី ខេត្ត
- សក្ដានុពលជាក់ស្ដែងដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
- គោលនយោបាយជាតិ។

បន្ទាប់ពីរៀបចំសេចក្ដីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយរួចក្រុមការងារកសាងផែនការរាជធានី ខេត្តត្រូវ៖

- បញ្ជូនសេចក្ដីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយ ទៅគណៈអភិបាលដើម្បីពិនិត្យ និងផ្ដល់យោបល់
- ក្នុងករណីចាំបាច់ ក្រុមការងារកសាងផែនការត្រូវកែសម្រួលសេចក្ដីព្រាងនេះផ្អែកតាមមតិយោបល់របស់គណៈអភិបាល
- បន្ទាប់មក បញ្ជូនសេចក្ដីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយនេះទៅក្រុមប្រឹក្សា ដើម្បីពិនិត្យ អនុម័ត និងចេញសេចក្ដីសម្រេចដាក់ឱ្យប្រើប្រាស់។

### ១.១.៤ ការរៀបចំបញ្ជីឯកសារពាក់ព័ន្ធនានា

ក) សមាសភាពចូលរួម

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត

ខ) លទ្ធផលរំពឹងទុក

- ឯកសារពាក់ព័ន្ធនានា
- បញ្ជីឯកសារពាក់ព័ន្ធ

គ) កិច្ចការដែលត្រូវធ្វើ

ដើម្បីរៀបចំបញ្ជីឯកសារពាក់ព័ន្ធនានាៈ

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត ប្រមូលឯកសារចាំបាច់សម្រាប់កសាងផែនការអភិវឌ្ឍន៍ មានដូចជា វឌ្ឍនភាពក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាថ្នាក់ក្រោមជាតិជាដើម។

### ១.២ កិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

ក) សមាសភាពចូលរួម

- តំណាងក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត
- តំណាងក្រុមប្រឹក្សាគ្រប់ក្រុង ស្រុក ខណ្ឌ
- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងគណៈកម្មាធិការផ្សេងទៀតរបស់ក្រុមប្រឹក្សារាជធានីខេត្ត
- តំណាងសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- តំណាងអង្គការសង្គមស៊ីវិលដែលមានក្នុងរាជធានី ខេត្ត
- តំណាងវិស័យឯកជន
- អ្នកពាក់ព័ន្ធដទៃទៀតតាមការចាំបាច់។

ខ) លទ្ធផលរំពឹងទុក

- អ្នកពាក់ព័ន្ធយល់ដឹងកាន់តែប្រសើរពីដំណើរការ និងកិច្ចការក្នុងការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

គ) កិច្ចការដែលត្រូវធ្វើ

ក្រុមការងារកសាងផែនការរាជធានី ខេត្តរៀបចំឯកសារសម្រាប់ធ្វើបទបង្ហាញ និងចែកជូនអ្នកពាក់ព័ន្ធឲ្យបានមុនកិច្ចប្រជុំពេញអង្គ។ របៀបវារៈសំខាន់ៗក្នុងកិច្ចប្រជុំ រួមមានៈ

- បទបង្ហាញអំពីៈ
  - ប្រកាសអន្តរក្រសួងស្ដីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានីខេត្ត
  - គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
  - ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
  - តារាងបូកសរុបការវិភាគស្ថានភាពរាជធានី ខេត្ត
  - ទិន្នន័យព័ត៌មានស្ថានភាពរាជធានី ខេត្ត
  - វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានៅថ្នាក់ក្រោមជាតិ
  - ប្រតិទិនការងារសម្រាប់ដំណើរកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។
- បញ្ហាផ្សេងៗ ។

**២.ជំហានទី២ ÷ ការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

ក) គោលបំណង

- ដើម្បីរៀបចំ និងចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានីខេត្ត

ខ) លទ្ធផលរំពឹងទុក

- សេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

គ) ដំណើរការ

ជំហានទី២ បែងចែកជា ៨សកម្មភាពដូចខាងក្រោមៈ

២.១ កិច្ចប្រជុំវិភាគស្ថានភាពរាជធានី ខេត្ត និងការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត

២.២ ការពិនិត្យ កែសម្រួល និងអនុម័តក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត

២.៣ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

២.៤ ការរៀបចំក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ

២.៥ ការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

២.៦ កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

២.៧ ការពិនិត្យនិងផ្តល់យោបល់របស់គណៈអភិបាលលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានីខេត្ត

២.៨ ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**២.១ កិច្ចប្រជុំវិភាគស្ថានភាព និងការរៀបចំសេចក្តីព្រាងក្របខំណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត**

ក) សមាសភាពចូលរួម

- គណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត
- តំណាងមន្ទីរវិស័យ និងអង្គភាពនានាក្នុងរាជធានីខេត្ត
- តំណាងក្រុមប្រឹក្សាក្រុងស្រុក ខណ្ឌក្នុងរាជធានី ខេត្ត
- តំណាងអង្គការសង្គមស៊ីវិលក្នុងរាជធានីខេត្ត
- តំណាងវិស័យឯកជនក្នុងរាជធានីខេត្ត

ខ) លទ្ធផលរំពឹងទុក

- តារាងវិភាគស្ថានភាពរាជធានី ខេត្ត ដែលបានចាត់អាទិភាព(តារាង២.១)
- សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត(តារាង២.២)

គ) កិច្ចការដែលត្រូវធ្វើ

១.ក្រុមការងារកសាងផែនការរាជធានី ខេត្ត ចែកតារាងបូកសរុបការវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ ដើម្បី ជាឯកសារយោងសម្រាប់ពិភាក្សា

២.អ្នកចូលរួមត្រូវ បានបែងចែកជាបួន (០៤)ក្រុម (ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកប្រើប្រាស់ដីធ្លី និងគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ និងផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ) ដើម្បីពិភាក្សា និងឯកភាពលើការចាត់អាទិភាពអំពីបណ្តាបញ្ហាកំពុងកើតមាន អាចនឹងកើតមាន មូលហេតុ និងដំណោះស្រាយនានាក្នុងអាណត្តិរបស់ក្រុមប្រឹក្សា ដោយត្រូវយកចិត្ត ទុកដាក់ចំពោះតម្រូវការ យេនឌ័រ (តារាង ១.២៖ តារាងវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ)។ នៅក្នុងការពិភាក្សាត្រូវប្រើប្រាស់ដើមឈើបញ្ហា និងដើមឈើដំណោះស្រាយជាឧបករណ៍វិភាគ (ឧបសម្ព័ន្ធ ២)។ ផ្នែកសេដ្ឋកិច្ច មានដូចជា អាជីវកម្ម កសិកម្ម ឧស្សាហកម្ម គមនាគមន៍ សេវាកម្ម ការវិនិយោគ ជាដើម។ ផ្នែកសង្គមកិច្ច មានដូចជា អប់រំ សុខាភិបាល យេនឌ័រ ភាពក្រីក្រ សាសនា អន្តោប្រវេសន៍ និងចំណាកស្រុក ជាដើម។ ផ្នែកគ្រប់គ្រង ដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និង ការគ្រប់គ្រងគ្រោះមហន្តរាយ មានដូចជា ការប្រើប្រាស់ដីធ្លី ធនធាន ធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយចម្បងៗ ការប្រែប្រួលអាកាសធាតុ ជាដើម។ ផ្នែករដ្ឋបាល និង សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ មានដូចជា អភិបាលកិច្ច ការគ្រប់គ្រងដែនដី ការគ្រប់គ្រងស្ថិតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ការងារព្រំដែន ជាដើម។

៣.បន្ទាប់ពីការវិភាគ ក្រុមនីមួយៗត្រូវ ពិនិត្យចាត់អាទិភាព និងត្រូវ ស្រង់លទ្ធផលនៃការពិភាក្សានេះទៅក្នុងសេចក្តីព្រាងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ ដោយត្រូវចម្លង៖

- *បញ្ហា មូលហេតុ* និង*តម្រូវការយេនឌ័រ* ចូលទៅក្នុងតារាងវិភាគស្ថានភាពរាជធានី ខេត្ត (តារាង២.១)
- *គោលបំណង គោលដៅ* និង*ដំណោះស្រាយ* ទៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍តាមផ្នែកនីមួយៗ (សូមមើលតារាង ២.២៖ តារាងក្របខ័ណ្ឌអភិវឌ្ឍន៍)

៤.ក្រុមនីមួយៗពិនិត្យភាពចាំបាច់ដើម្បីបញ្ចូលបញ្ហាជាអាទិភាពដែលទទួលបានពីការ វិភាគស្ថានភាពរបស់ក្រុង ស្រុក ខណ្ឌ ហើយដែលមិនបានលើកឡើងដោយក្រុមពិភាក្សា។

៥.ក្រុមនីមួយៗ ត្រូវធ្វើបទបង្ហាញពីលទ្ធផលនៃកិច្ចពិភាក្សារបស់ខ្លួននៅក្នុងកិច្ចប្រជុំ ដើម្បីពិនិត្យ ពិភាក្សា កែសម្រួល

## ២.២ ការពិនិត្យ កែសម្រួល និងអនុម័តក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត

**ក) សមាសភាពចូលរួម**

- តំណាងក្រុមប្រឹក្សារាជធានីខេត្ត
- គណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត
- គណៈកម្មាធិការនានានៃក្រុមប្រឹក្សារាជធានីខេត្ត
- អ្នកពាក់ព័ន្ធសំខាន់ៗដែលមានចំណេះដឹងនិងបទពិសោធន៍។

**ខ) លទ្ធផលរំពឹងទុក**

- ក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្តដែលបានអនុម័ត

**គ) កិច្ចការដែលត្រូវធ្វើ**

១.ក្រុមការងារកសាងផែនការពិនិត្យ កែសម្រួល និងរៀបចំបញ្ចប់សេចក្ដីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ (តារាង២.២)។ ក្នុងកិច្ចការនេះ ក្រុមការងារកសាងផែនការ ត្រូវអញ្ជើញតំណាងក្រុមប្រឹក្សារាជធានី ខេត្ត គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីខេត្ត និងអ្នកពាក់ព័ន្ធសំខាន់ៗ ដែលមានចំណេះដឹង និងបទពិសោធន៍ក្នុងការងារនេះ ដើម្បីចូលរួមផ្ដល់មតិយោបល់។

២.គណៈអភិបាលរាជធានី ខេត្តត្រូវផ្ញើសេចក្ដីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ជូនក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងអនុម័តដើម្បីជាមូលដ្ឋានសម្រាប់រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ជាពិសេសការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលលើកទី១

៣.ក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនដើម្បីពិនិត្យ និងអនុម័តសេចក្ដីព្រាងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត។

## ២.៣ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

ផ្អែកតាមទំហំនៃសូចនាករអភិវឌ្ឍន៍ដែលបានសរសេរខាងលើ ត្រូវធ្វើការគណនាប៉ាន់ស្មានអំពីតម្រូវការថវិកាចំណាយ។ ថវិកាចំណាយមានពីរផ្នែក គឺផ្នែកចំណាយចរន្ត និងផ្នែកចំណាយមូលធន។ ទោះបីជាថវិកាចំណាយនេះមិនទាន់មានលក្ខណៈត្រឹមត្រូវនៅឡើយក៏ដោយ ក៏ថវិកាចំណាយនេះបង្ហាញឱ្យឃើញពីភាពម្ចាស់ការក្នុងកម្រិតណាមួយរបស់រាជធានី ខេត្ត នៅពេលបំលែងសូចនាករអភិវឌ្ឍន៍៥ឆ្នាំទៅជាទំហំនៃគម្រោងការងារ ឬសកម្មភាពអភិវឌ្ឍន៍ប្រចាំឆ្នាំ។ សេចក្ដីណែនាំលម្អិតសម្រាប់រៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនឹងធ្វើការណែនាំជាក្រោយ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ២.៤ ការរៀបចំក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**ក) សមាសភាពចូលរួម**

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត

**ខ) លទ្ធផលរំពឹងទុក**

- ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**គ) កិច្ចការដែលត្រូវធ្វើ**

១.ក្រុមការងារផែនការរាជធានី ខេត្តត្រូវរៀបចំក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

២. ក្រុមការងារផែនការរាជធានី ខេត្តត្រូវរៀបចំនីតិវិធីអនុវត្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

### ២.៤.១៖ ការរៀបចំក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការអភិវឌ្ឍន៍រាជធានីខេត្ត

១. ក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវទទួលខុសត្រូវក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ជារៀងរាល់ឆ្នាំលើការអនុវត្តផែនការអភិវឌ្ឍន៍ ដោយរាប់ទាំងផ្នែកនានានៃផែនការអភិវឌ្ឍន៍ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់៖

- ក្រុមប្រឹក្សាប្រភេទរួមគ្នា
- ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត
- ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល
- អ្នកពាក់ព័ន្ធនានា។

២. រៀបចំយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ ដោយត្រូវផ្តោតលើ ចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- ការរៀបចំផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍
- ការកំណត់សូចនាករសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍
- ការកំណត់អ្នកទទួលខុសត្រូវក្នុងការតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍
- ការកំណត់វិធីសាស្ត្រតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍
- ការកំណត់អ្នកចូលរួមក្នុងការតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍។

**២.៤.២៖ ការរៀបចំនីតិវិធីអនុវត្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការអភិវឌ្ឍន៍រាជធានីខេត្ត**

១. នៅអំឡុងត្រីមាសទី៤ គណៈអភិបាលរាជធានី ខេត្ត ដោយមាន ទីចាត់ការផែនការនិងវិនិយោគ ជាសេនាធិការត្រូវប្រមូលទិន្នន័យដើម្បីបញ្ចូលក្នុងតារាងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ហើយត្រូវរៀបចំសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តផែនការអភិវឌ្ឍន៍ ដោយសហការជាមួយតំណាងមន្ទីរនិងទីចាត់ការនានា។ (សូមមើលតារាង ២.៣៖ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ)

ខ្លឹមសាររបាយការណ៍នេះរួមមាន ៖

- វឌ្ឍនភាពការងារអនុវត្តក្នុងឆ្នាំកន្លងមក
- ទិសដៅការងារសម្រាប់អនុវត្តឆ្នាំខាងមុខ
- សេចក្តីសន្និដ្ឋានរួម។

២. គណៈអភិបាលរាជធានី ខេត្ត ត្រូវពិនិត្យ និងកែសម្រួលសេចក្តីព្រាងរបាយការណ៍ បន្ទាប់មកត្រូវដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

៣. ប្រសិនបើចាំបាច់ ក្រុមប្រឹក្សារាជធានី ខេត្តពិនិត្យវឌ្ឍនភាពរបស់សូចនាករ និងឧបសគ្គ ហើយផ្តល់ការណែនាំសំខាន់ៗ ព្រមទាំងអនុម័តសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ។

៤. ក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវធ្វើការណែនាំដល់គណៈអភិបាលរាជធានី ខេត្ត ដើម្បីផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំដែលបានអនុម័តនេះ ជូនដល់អ្នកពាក់ព័ន្ធ ។

៥. គណៈអភិបាលរាជធានី ខេត្ត ត្រូវធ្វើការវាយតម្លៃអំពីលទ្ធផល សមិទ្ធផល និងផលប៉ះពាល់នៃការអនុវត្តផែនការអភិវឌ្ឍន៍ក្នុងរយៈពេលប្រាំមួយ(០៦)ខែចុងក្រោយ នៃអាណត្តិរបស់ក្រុមប្រឹក្សាប្រកបដោយប្រសិទ្ធភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ។

**២.៥ ការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

ក) *សមាសភាពចូលរួម*

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត

ខ) *លទ្ធផលរំពឹងទុក*

- សេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានីខេត្ត

គ) *កិច្ចការដែលត្រូវធ្វើ*

១. ផ្អែកតាមមាតិកាដូចមានកំណត់នៅក្នុងទម្រង់សៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្តក្រុមការងារកសាងផែនការ ត្រូវរៀបចំសេចក្តីព្រាងសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។

២. ក្នុងករណីចាំបាច់ ក្រុមការងារកសាងផែនការរាជធានី ខេត្ត អាចស្នើសុំពិគ្រោះយោបល់ជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ។

## ២.៦ កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ រាជធានី ខេត្ត

ក) សមាសភាពចូលរួម

- ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានីខេត្ត
- តំណាងក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានីខេត្ត
- តំណាងក្រុមប្រឹក្សាគ្រប់ក្រុង ស្រុក ខណ្ឌ
- តំណាងក្រុមប្រឹក្សាគ្រប់សង្កាត់ក្នុងរាជធានីខេត្ត
- សមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសនិងគណៈកម្មាធិការពាក់ព័ន្ធផ្សេងទៀត
- តំណាងអង្គការ សង្គមស៊ីវិលពាក់ព័ន្ធក្នុងរាជធានីខេត្ត
- អ្នកពាក់ព័ន្ធដទៃទៀតតាមការចាំបាច់។

ខ) លទ្ធផលរំពឹងទុក

- សេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានីខេត្ត ដែលបានកែសម្រួល

គ) កិច្ចការដែលត្រូវធ្វើ

១.ក្រុមការងារកសាងផែនការ រៀបចំឯកសារដូចខាងក្រោម សម្រាប់កិច្ចប្រជុំពិគ្រោះយោបល់

- របៀបវារៈនៃកិច្ចប្រជុំ
- បទបង្ហាញស្តីពីខ្លឹមសារសំខាន់ៗនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- លិខិតអញ្ជើញដោយភ្ជាប់ជាមួយនូវសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ឯកសារចាំបាច់ផ្សេងៗទៀតដែលស្នើឡើងដោយគណៈអភិបាល។

២.កិច្ចប្រជុំពិគ្រោះយោបល់គួរប្រព្រឹត្តទៅតាមរបៀបវារៈដូចខាងក្រោម ៖

- បទបង្ហាញពីឯកសារនានាដែលរៀបចំ ដោយក្រុមការងារកសាងផែនការរាជធានី ខេត្ត
- ក្នុងករណីចាំបាច់ អង្គប្រជុំអាចធ្វើការបែងចែកអ្នកចូលរួមជាក្រុម ដើម្បីពិភាក្សាលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្នុងនោះអាចមានប្រធានបទសំខាន់ៗដូចជា៖ ចក្ខុវិស័យអភិវឌ្ឍន៍ គោលបំណង គោលដៅ យុទ្ធសាស្ត្រអភិវឌ្ឍន៍និងស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម ។ល។

៣.ក្រុមការងារកសាងផែនការ កែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ផ្អែកលើលទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់។

## ២.៧ ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

ក) សមាសភាពចូលរួម

- គណៈអភិបាលរាជធានី ខេត្ត

ខ) លទ្ធផលរំពឹងទុក

- សេចក្តីព្រាងផែនការអភិវឌ្ឍន៍ដែលបានកែសម្រួល

គ) កិច្ចការដែលត្រូវធ្វើ

- គណៈអភិបាលរាជធានីខេត្ត ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ក្រុមការងារកសាងផែនការ កែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ផ្អែកតាមមតិយោបល់របស់គណៈអភិបាល។

## ២.៨ ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

ក) សមាសភាពចូលរួម

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

ខ) លទ្ធផលរំពឹងទុក

- សេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្តដែលបានកែសម្រួល

គ) កិច្ចការដែលត្រូវធ្វើ

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី ខេត្ត ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍មុនដាក់ជូនក្រុមប្រឹក្សា
- ក្រុមការងារកសាងផែនការ កែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ផ្អែកតាមមតិយោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស។

## ៣.ជំហានទី៣ ៖ ការអនុម័ត និងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

ក) គោលបំណង

- ដើម្បីពិនិត្យ អនុម័ត និងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍រាជធានីខេត្ត សម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា និង ដើម្បីប្រើប្រាស់ជាមូលដ្ឋានក្នុងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានីខេត្ត ។

ខ) លទ្ធផលរំពឹងទុក

- ផែនការអភិវឌ្ឍន៍រាជធានីខេត្ត ដែលបានអនុម័ត
- ខ្លឹមសារផែនការអភិវឌ្ឍន៍បានផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ។

គ) ដំណើរការ

ជំហានទី៣ រួមមាន ២សកម្មភាព ដូចខាងក្រោម៖

៣.១ ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

៣.២ ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

### ៣.១ ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

### ៣.១.១ ការងារមុនកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត

ក) សមាសភាពចូលរួម

- គណៈអភិបាលរាជធានីខេត្ត
- ក្រុមការងារកសាងផែនការាជធានី ខេត្ត
- ទីចាត់ការផែនការ និងវិនិយោគនៃសាលារាជធានីខេត្ត
- នាយករដ្ឋបាលនៃសាលារាជធានី ខេត្ត
- អ្នកពាក់ព័ន្ធ និងអ្នកសង្កេតការណ៍នានាចូលរួមតាមការអនុញ្ញាតពីប្រធានក្រុមប្រឹក្សារាជធានីខេត្ត។

ខ) លទ្ធផលរំពឹងទុក

- របៀបវារៈនៃកិច្ចប្រជុំ
- សេចក្តីថ្លែងហេតុ
- ឯកសារបទបង្ហាញអំពីសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- លិខិតអញ្ជើញ

គ) កិច្ចការដែលត្រូវធ្វើ

- ក្រុមការងារកសាងផែនការដោយមានជំនួយពីទីចាត់ការផែនការនិងវិនិយោគ និងនាយករដ្ឋបាលនៃសាលារាជធានី ខេត្ត ត្រូវរៀបចំកិច្ចការសំខាន់ៗដូចខាងក្រោម៖
  - រៀបចំរបៀបវារៈនៃកិច្ចប្រជុំ
  - រៀបចំសេចក្តីថ្លែងហេតុ
  - រៀបចំឯកសារបង្ហាញអំពីសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
  - រៀបចំ និងបញ្ជូន លិខិតអញ្ជើញ ដោយភ្ជាប់ជាមួយនូវសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និងឯកសារពាក់ព័ន្ធផ្សេងៗទៀត (ឯកសារទាំងនេះត្រូវផ្ញើជូនអ្នកពាក់ព័ន្ធនានាឱ្យបាន យ៉ាងតិច៣ថ្ងៃ មុនកិច្ចប្រជុំ)
  - រៀបចំកិច្ចការចាំបាច់ផ្សេងៗទៀតតាមការណែនាំរបស់អភិបាលរាជធានី ខេត្ត។

### ៣.១.២ កិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត

ក) *សមាសភាពចូលរួម*

- ក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈអភិបាលរាជធានីខេត្ត
- ក្រុមការងារកសាងផែនការ
- អ្នកពាក់ព័ន្ធផ្សេងៗទៀត។

ខ) *លទ្ធផលរំពឹងទុក*

- ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ត្រូវបានពិនិត្យកែសម្រួលនិងអនុម័តដោយក្រុមប្រឹក្សារាជធានីខេត្ត

គ) *កិច្ចការដែលត្រូវធ្វើ*

១. អភិបាលរាជធានី ខេត្តអានសេចក្តីថ្លែងហេតុ និងធ្វើបទបង្ហាញអំពីសេចក្តីព្រាងផែនការអភិវឌ្ឍន៍។

២. ក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ ពិភាក្សា និងអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។ កិច្ចប្រជុំពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ត្រូវដំណើរការតាមនីតិវិធី និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត។

### ៣.១.៣ ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សារាជធានីខេត្ត

**១. ការកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

គណៈអភិបាលរាជធានី ខេត្ត ត្រូវធ្វើការកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ដោយផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ហើយដាក់ជូនអភិបាលរាជធានី ខេត្ត នូវសេចក្តីព្រាងផែនការដែលបានកែសម្រួលនេះ ដើម្បីពិនិត្យ និងធ្វើជូនលេខាធិការដ្ឋាន គ.ជ.អ.ប ។

**២. ការផ្តល់អនុលោមភាពលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

បន្ទាប់ពីទទួលបានសេចក្តីព្រាងផែនការអភិវឌ្ឍន៍ពីអភិបាលរាជធានី ខេត្ត លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវធ្វើការថតចម្លងសេចក្តីព្រាងនេះជូនក្រសួងមហាផ្ទៃ ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវធ្វើការសម្របសម្រួល ពិនិត្យ ពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ជាមួយក្រសួងទាំងបីខាងលើនេះ ព្រមទាំងជាមួយស្ថាប័នពាក់ព័ន្ធនានា ដើម្បីពិនិត្យ និងផ្តល់យោបល់លើភាពស្របច្បាប់ និងសង្គតិភាពនៃផែនការនេះជាមួយគោលនយោបាយជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ ក្រោយពេលពិនិត្យ និងពិគ្រោះយោបល់រួចរាល់ហើយ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវ ធ្វើកំណត់បង្ហាញសុំយោបល់មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។

ការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ត្រូវធ្វើឡើងក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលទទួលបានការស្នើសុំពិនិត្យ និងផ្តល់យោបល់របស់អភិបាលរាជធានី ខេត្ត។ រយៈពេល៣០ថ្ងៃនេះរួមមាន៖ ពេលវេលាចំណាយសម្រាប់ការពិគ្រោះយោបល់ជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ការធ្វើទំនាក់ទំនងជាមួយអភិបាលរាជធានី ខេត្ត ដើម្បីស្រាយបំភ្លឺ និងឯកភាពលើយោបល់ដែលផ្តល់ដោយក្រសួងមហាផ្ទៃលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។

ក្នុងករណីមិនមានការឯកភាពគ្នារវាងអភិបាលរាជធានី ខេត្ត និងក្រសួងមហាផ្ទៃអំពីខ្លឹមសារសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រសួងមហាផ្ទៃត្រូវរាយការណ៍ និងស្នើសុំមកលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីធ្វើការសម្របសម្រួលដោះស្រាយ។

ក្នុងរយៈពេល៣០ថ្ងៃ បើគ្មានការឆ្លើយតបជាលាយលក្ខណ៍អក្សរពីក្រសួងមហាផ្ទៃផ្ញើទៅអភិបាល រាជធានី ខេត្តទេនោះសេចក្តីព្រាងផែនការអភិវឌ្ឍន៍ត្រូវចាត់ទុកថាទទួលបានអនុលោមភាពពីក្រសួងមហាផ្ទៃ។

ក្នុងករណីមានយោបល់កែសម្រួលលើសេចក្តីផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ដោយក្រសួងមហាផ្ទៃ គណៈអភិបាលរាជធានី ខេត្ត ធ្វើការពិចារណា និងកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ទៅតាមយោបល់ដែលទទួលបាន ហើយដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងអនុម័តឡើងវិញដោយផ្តោតតែលើចំណុចដែលបានកែសម្រួលប៉ុណ្ណោះ។

## ៣. សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

បន្ទាប់ពីទទួលបានការផ្តល់អនុលោមភាពពីក្រសួងមហាផ្ទៃ គណៈអភិបាលត្រូវរៀបចំសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និងដាក់ជូនប្រធានក្រុមប្រឹក្សាចុះហត្ថលេខា។ ក្នុងករណីចាំបាច់ ក្រុមប្រឹក្សារាជធានី ខេត្ត អាចធ្វើការកែតម្រូវផែនការអភិវឌ្ឍន៍ក្នុងអំឡុងពេលនៃការអនុវត្តផែនការនេះ។

## ៣.២ ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

### ៣.២.១ ការបោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

គណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំបោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ហើយត្រូវតម្កល់ទុកនៅសាលារាជធានី ខេត្ត មន្ទីរផែនការរាជធានី ខេត្ត និងផ្ញើទៅក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធដទៃទៀត។

### ៣.២.២ ការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

១. ក្រុមប្រឹក្សាត្រូវណែនាំដល់គណៈអភិបាលរាជធានី ខេត្ត ដើម្បីផ្សព្វផ្សាយខ្លឹមសារផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ។

២. ការផ្សព្វផ្សាយអាចធ្វើឡើងតាមរយៈមធ្យោបាយផ្សេងៗដូចជាសារព័ត៌មាន កិច្ចប្រជុំផ្សព្វផ្សាយក្តារព័ត៌មាន ។ល។

# ផ្នែកទី៤
# ទម្រង់សៀវភៅនិងសេចក្តីណែនាំលំអិតស្តីពីការរៀបចំផែនការអភិវឌ្ឍន៍រាជធានីខេត្ត

## ៤.១ ទម្រង់សៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

អារម្ភកថា

សេចក្តីផ្តើម

ផែនទីរាជធានី ខេត្ត

**ជំពូកទី១ ÷ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច**

១.១ សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច

១.២ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

១.២.១ ស្ថានភាពសេដ្ឋកិច្ច

១.២.២ ស្ថានភាពសង្គមកិច្ច

១.២.៣ ស្ថានភាពនៃការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

១.២.៤ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

**ជំពូកទី២ ÷ ក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត**

២.១ ចក្ខុវិស័យអភិវឌ្ឍន៍

២.២ គោលបំណងអភិវឌ្ឍន៍

២.៣ គោលដៅអភិវឌ្ឍន៍

២.៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍

២.៤.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច

២.៤.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច

២.៤.៣ យុទ្ធសាស្ត្រប្រើប្រាស់ដីធ្លី និងគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

២.៤.៤ យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

២.៥. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

**ជំពូកទី៣ ÷ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

**ឧបសម្ព័ន្ធ**

## ៤.២ សេចក្តីពន្យល់ពីខ្លឹមសារសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

- **សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

  បន្ទាប់ពីទំព័រគម្របសៀវភៅ គឺជាសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍រាជធានីខេត្ត។ ខ្លឹមសារសំខាន់ៗដែលត្រូវបញ្ចូលក្នុងសេចក្តីសម្រេចមានដូចជា ការប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ការណែនាំដល់គណៈអភិបាលរាជធានី ខេត្តក្នុងការផ្សព្វផ្សាយការអនុវត្ត និងការតាមដាននិងការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍រាជធានីខេត្ត។ សេចក្តីសម្រេចនេះត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សារាជធានីខេត្ត។

- **អារម្ភកថា**

  បន្ទាប់ពីទំព័រមាតិកា គឺទំព័រអារម្ភកថាដែលត្រូវរក្សាក្នុងទំព័រមួយដាច់ដោយឡែក។ អារម្ភកថាមិនគួរសរសេរវែងពេក (យ៉ាងច្រើនត្រឹមមួយទំព័រ)។ អារម្ភកថាត្រូវបង្ហាញពីសារប្រយោជន៍នៃផែនការអភិវឌ្ឍន៍ ការថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមកសាងផែនការអភិវឌ្ឍន៍ និងសេចក្តីសង្ឃឹមដែលនឹងទទួលបានការគាំទ្រពីអ្នកពាក់ព័ន្ធ។

- **សេចក្តីផ្តើម**

  បន្ទាប់ពីទំព័រអារម្ភកថា គឺសេចក្តីផ្តើម ។ សេចក្តីផ្តើមត្រូវសរសេរពីមូលហេតុដែលនាំឱ្យមានការរៀបចំផែនការអភិវឌ្ឍន៍ គោលបំណង និងសង្ខេបដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍ ។ សេចក្តីផ្តើមគួរសរសេរសង្ខេបឲ្យខ្លី។

- **ផែនទីរាជធានី ខេត្ត**

  គប្បីប្រើផែនទីរាជធានី ខេត្តដែលបង្ហាញពីលក្ខណៈភូមិសាស្ត្រ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ និងរដ្ឋបាលក្នុងរាជធានី ខេត្ត ។ ផែនទីនេះគួររៀបចំនៅលើក្រដាសទំហំ A3 ។ និមិត្តសញ្ញាសម្រាប់តាងឱ្យវត្ថុដែលកំពុងមានក្នុងរាជធានី ខេត្ត គួរត្រូវប្រើដូចជា និមិត្តសញ្ញានៃប្រព័ន្ធផ្លូវថ្នល់ ស្ពាន លូរំដោះទឹក ប្រព័ន្ធប្រឡាយទឹក ទីតាំងរដ្ឋបាល ទីតាំងសាលារៀន ទីតាំងផ្តល់សេវាសុខភាពសាធារណៈ ទីតាំងសាសនា វាលស្រែ ធនធានធម្មជាតិ ។

## ជំពូកទី១ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច

### ១.១. សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច

ព័ត៌មានសំខាន់ៗក្នុងរាជធានី ខេត្ត

| បរិយាយ | ឯកតា | ឆ្នាំ២០១៤ |
|---|---|---|
| ផ្ទៃដីរាជធានី ខេត្ត | គ.ម២ | |
| ចំនួនក្រុង ស្រុក ខណ្ឌ | ក្រុង ស្រុក ខណ្ឌ | |
| ចំនួនឃុំ សង្កាត់ | ឃុំ សង្កាត់ | |
| ចំនួនភូមិ | ភូមិ | |
| ចំនួនប្រជាជនសរុប | នាក់ | |
| ចំនួនស្ត្រីសរុប | នាក់ | |
| កំណើនប្រជាជនប្រចាំឆ្នាំ | % | |
| ចំនួនគ្រួសារសរុប | គ្រួសារ | |
| អត្រាមេគ្រួសារជាស្ត្រី | % | |
| អត្រាគ្រួសារមានមុខរបរ..........ជាចម្បង | % | |
| អត្រាកុមារអាយុ៦-១៤ឆ្នាំ មិនបានចូលរៀន | % | |
| អត្រាអ្នកមិនចេះអក្សរអាយុពី១៥-៦០ឆ្នាំ | % | |
| អត្រាស្ត្រីមិនចេះអក្សរអាយុពី១៥-៦០ឆ្នាំ | % | |
| ចំនួនស្ត្រីសម្រាលកូន | នាក់ | |
| អត្រាស្ត្រីសម្រាលកូនដោយពេទ្យឆ្មប | % | |
| មរណភាពមាតាក្នុង១០ម៉ឺនកំណើតក្រោយពេលសម្រាលកូនពី០-១ខែ | នាក់ | |
| អត្រាគ្រួសារប្រើប្រាស់ទឹកម៉ាស៊ីន | % | |
| អត្រាគ្រួសារប្រើប្រាស់អណ្តូងទឹកស្អាត | % | |
| សមាមាត្រគ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | % | |

តួលេខដែលយកមកបំពេញក្នុងតារាងខាងលើនេះត្រូវស្រង់ចេញពីសៀវភៅទិន្នន័យភូមិ ឃុំ សង្កាត់ និងឯកសារព័ត៌មានស្ថានភាពរាជធានី ខេត្ត ដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយគេ។ តួលេខមួយចំនួនដូចជាផ្ទៃដី ចំនួនភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ នោះរាជធានី ខេត្ត ត្រូវបំពេញដោយខ្លួនឯង។ ខេត្តអាចបន្ថែមព័ត៌មានផ្សេងទៀតដែលខ្លួនយល់ថាមានសារៈសំខាន់ដល់ការរំលេចគុណភាពផែនការអភិវឌ្ឍន៍របស់ខ្លួនដូចជាសូចនាករនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ គោលដៅ និងចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តែមិនគួរបន្ថែមច្រើនពេក នាំឱ្យព័ត៌មានទាំងនោះប្រែជាមិនសំខាន់ទៅវិញ។

### ១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

ក្នុងចំណុចនេះ ត្រូវរៀបរាប់អំពីអ្វីខ្លះដែលរាជធានី ខេត្តមានសក្តានុពលសម្រាប់បម្រើឱ្យសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងអ្វីខ្លះដែលជាឧបសគ្គ ឬជាបញ្ហាប្រឈមដល់ការអភិវឌ្ឍន៍ និងការឆ្លើយតបទៅនឹងសេចក្តីត្រូវការទាំងនោះ។

ការសរសេរពីស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមត្រូវផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាពក្នុងជំហានទី២នៃដំណើរការកសាងផែនការអភិវឌ្ឍន៍។ ក្នុងការបរិយាយ អាចបញ្ចូលតារាងទិន្នន័យ ឬក្រាហ្វិកសំខាន់ៗ និងត្រូវអនុវត្តតាមលំដាប់លំដោយដូចខាងក្រោម៖

### ១.២.១. ស្ថានភាពសេដ្ឋកិច្ច

ក្នុងចំណុចនេះ រាជធានី ខេត្តត្រូវធ្វើការកំណត់ និងសរសេរតាមបែបវិភាគអំពីសកម្មភាពសេដ្ឋកិច្ចចម្បងៗ និងបន្ទាប់បន្សំមួយចំនួនដែលមានក្នុងរាជធានី ខេត្ត ដោយផ្អែកលើលទ្ធផលវិភាគផ្នែកសេដ្ឋកិច្ច ។

សកម្មភាពសេដ្ឋកិច្ចចម្បង គឺសំដៅលើសកម្មភាពដែលប្រជាពលរដ្ឋភាគច្រើនក្នុងរាជធានី ខេត្ត អនុវត្តដើម្បីយកផលមកធ្វើជាកម្លាំងស្នូលក្នុងការទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ។ ចំណែកឯសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំគឺ សំដៅលើសកម្មភាពដែលប្រជាពលរដ្ឋមួយចំនួនក្នុងរាជធានី ខេត្ត អនុវត្តដើម្បីរកកម្រៃបន្ថែមសម្រាប់ការទ្រទ្រង់ជីវភាព (ទោះបីជាបរិមាណចំណូលពីសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំអាចច្រើនជាងចំណូលពីសកម្មភាពសេដ្ឋកិច្ចចម្បងក៏ដោយ) ។

ឧទាហរណ៍៖ ក្នុងរាជធានីដែលមានប្រជាពលរដ្ឋភាគច្រើនប្រកបរបរជាអាជីវករដូច្នេះសកម្មភាពសេដ្ឋកិច្ចចម្បងគឺអាជីវកម្ម ទោះបីជាចំណូលពីអាជីវកម្មរបស់ប្រជាពលរដ្ឋម្នាក់ៗ អាចមានទាបជាងចំណូលពីសកម្មភាពផ្សេងក៏ដោយ។ ដូច្នេះត្រូវវិភាគស្ថានភាពអាជីវកម្មជាក់ស្តែងក្នុងរាជធានី ដោយពិនិត្យពីកត្តាអ្វីខ្លះដែលបានជំរុញ និងអ្វីខ្លះជាឧបសគ្គដល់ការឈានឡើងទាំងចំពោះមុខ និងយូរអង្វែងរបស់វិស័យអាជីវកម្មក្នុងរាជធានី ហើយដែលកំពុងជះឥទ្ធិពលលើកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋពិសេសអាជីវករក្នុងរាជធានី។ ទន្ទឹមនេះត្រូវបរិយាយពីអ្វីខ្លះដែលនាំឱ្យមានការផ្លាស់ប្តូរក្នុងមុខរបរជំនួញ (ឧទាហរណ៍៖ កត្តាសេដ្ឋកិច្ចប្រែប្រួល) ហើយអ្វីខ្លះដែលរាជធានីត្រូវធ្វើការព្យាយាមទប់ស្កាត់ឬគ្រប់គ្រងការផ្លាស់ប្តូរទាំងនេះ ដើម្បីធានានិរន្តរភាព និងភាពរីកចម្រើនក្នុងវិស័យអាជីវកម្មនេះ ។

ចំពោះខេត្តដែលមានប្រជាពលរដ្ឋភាគច្រើនប្រកបរបរធ្វើស្រែសកម្មភាពសេដ្ឋកិច្ចចម្បងសម្រាប់ខេត្តនោះគឺកសិកម្ម ទោះបីជាចំណូលបានមកពីការធ្វើស្រែរបស់ប្រជាកសិករម្នាក់ៗអាចមានទាបជាងចំណូលពីសកម្មភាពផ្សេងក៏ដោយ។ ការរៀបរាប់ស្ថានភាពសេដ្ឋកិច្ចរបស់ខេត្តដែលមានសកម្មភាពសេដ្ឋកិច្ចចម្បងគឺ កសិកម្មមានលក្ខណៈដូចគ្នានឹងការរៀបរាប់ស្ថានភាពសេដ្ឋកិច្ចរបស់រាជធានី ដូចមានរៀបរាប់ខាងលើ។

សកម្មភាពចម្បងក្នុងផ្នែកសេដ្ឋកិច្ចរួមមាន ៖

**អាជីវកម្ម ៖** មុខរបរសំខាន់ៗក្នុងវិស័យអាជីវកម្មរួមមាន មុខរបរជំនួញ ប្រភេទសិប្បកម្មនានា ជាងជួសជុល។ល។ ក្នុងស្ថានភាពអាជីវកម្ម ត្រូវសរសេររៀបរាប់អំពីសក្តានុពលសំខាន់ៗរបស់រាជធានី ខេត្ត និងបញ្ហាប្រឈមនានាដែលរាជធានី ខេត្តកំពុងជួបប្រទះ។

**កសិកម្ម៖** សកម្មភាពសំខាន់ៗក្នុងវិស័យកសិកម្មរួមមាន ការដាំដុះស្រូវ ដំណាំកសិឧស្សាហកម្ម និងដំណាំរួមផ្សំ ការចិញ្ចឹមសត្វនិងត្រី ការប្រើប្រាស់ជីផ្លី និងប្រព័ន្ធធារាសាស្ត្រដែលជួយគាំទ្រដល់ការងារកសិកម្ម។ ក្នុងស្ថានភាពកសិកម្ម ត្រូវសរសេររៀបរាប់អំពីសក្តានុពលសំខាន់ៗរបស់រាជធានី ខេត្ត និងបញ្ហាប្រឈមនានាក្នុងរាជធានី ខេត្តកំពុងជួបប្រទះ។

**ឧស្សាហកម្ម ៖** សកម្មភាពសំខាន់ៗក្នុងវិស័យឧស្សហកម្មរួមមាន សកម្មភាពសិប្បកម្ម រោងចក្រ និងការងារសំណង់ជាដើម។ ដូច្នេះ ត្រូវសរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗដែលពាក់ព័ន្ធនឹងវិស័យនេះ។

**គមនាគមន៍ ៖** សរសេររៀបរាប់អំពីសក្តានុពលនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវគោកនិងផ្លូវទឹកដែលរាជធានីខេត្តមាន និងបញ្ហាប្រឈមសំខាន់ៗដែលរាជធានី ខេត្តកំពុងជួបប្រទះ។

**សេវាកម្ម ៖** សរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមនៃសេវាកម្មនានាពាក់ព័ន្ធនឹងពាណិជ្ជកម្ម សាធារណការ ទឹកស្អាត អគ្គិសនី ទីផ្សារ ទេសចរណ៍ និងសេវាឯកជនផ្សេងទៀត។

**ការវិនិយោគ ៖** ចំណុចនេះត្រូវសរសេររៀបរាប់អំពីទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរវាងវិស័យឯកជនជាមួយរាជធានី ខេត្ត ដើម្បីរៀបចំគម្រោងអភិវឌ្ឍន៍នានានៅក្នុងរាជធានី ខេត្តដូចជា ការអភិវឌ្ឍន៍ផ្សារ ចំណតរថយន្ត ផ្លូវ ស្ពាន និងគម្រោងអភិវឌ្ឍន៍ផ្សេងទៀត។ ដូច្នេះ ត្រូវសរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗ ដែលពាក់ព័ន្ធនឹងការវិនិយោគនេះ។

**ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ៖** ត្រូវសរសេររៀបរាប់អំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយពាណិជ្ជករ ឬក្រុមហ៊ុនក្នុងក្រៅស្រុក ឬកិច្ចសហប្រតិបត្តិការ ឬការចងសម្ព័ន្ធមេត្រីភាពរវាងរាជធានី ខេត្ត និងប្រទេសជិតខាង ដើម្បីអភិវឌ្ឍន៍រាជធានី ខេត្តដូចជា ការបង្កើតតំបន់អភិវឌ្ឍន៍ក្នុងរាជធានីខេត្ត ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ការការពារទឹកជំនន់ និងការអភិវឌ្ឍន៍ទីផ្សារជាដើម។ ដូច្នេះត្រូវសរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗដែលពាក់ព័ន្ធនឹងការងារនេះ ។

ក្រៅពីចំណុចសំខាន់ដែលបានរៀបរាប់ខាងលើរាជធានី ខេត្តអាចបន្ថែមនូវចំណុចផ្សេងទៀតដែលរាជធានីខេត្តយល់ថាចាំបាច់ និងគួរបញ្ចូលក្នុងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។ ការសរសេររៀបរាប់ចំណុចបន្ថែមនេះគឺដូចគ្នានឹងចំណុចនានាខាងលើដោយផ្តោតលើសក្តានុពល និងបញ្ហាប្រឈមនានា ។

### ១.២.២. ស្ថានភាពសង្គមកិច្ច

ស្ថានភាពសង្គមកិច្ច ជាផ្នែកមួយដែលត្រូវធ្វើការសិក្សាពីលក្ខណៈប្រជាសាស្ត្រ សេវាសាធារណៈផ្នែកសង្គម និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋនៅក្នុងរាជធានី ខេត្ត ដូចជា ស្ថានភាពអប់រំ សុខុមាលភាព យេនឌ័រ ភាពក្រីក្រ អំពើហិង្សា ការជួញដូរស្ត្រីនិងកុមារ ការលើកកម្ពស់សិទ្ធិមនុស្ស និងស្ថានភាពសាសនាជាដើម។ ការសរសេរអំពីស្ថានភាពសង្គមកិច្ច ត្រូវសរសេរជាលក្ខណៈវិភាគដោយផ្អែកលើលទ្ធផលនៃការវិភាគសង្គមកិច្ច និងត្រូវផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

**អប់រំ ៖** សរសេរពីការសម្រេចបានរបស់វិស័យអប់រំដូចជា ការសិក្សារបស់កុមារស្តង់ដារអប់រំ (ការចូលរៀនរបស់កុមារនៅថ្នាក់មត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យ ការបោះបង់ចោលការសិក្សា ការរៀនត្រួតថ្នាក់ ពិសេសក្មេងស្រី ការងារអក្ខរកម្ម...) ។

**សុខាភិបាល ៖** សរសេរពីស្ថានភាពសុខភាពរបស់ប្រជាជន ពិសេសស្ត្រីនិងកុមារ កម្រិតទទួលបានសេវាសុខភាព អត្រាមរណភាពមាតា និងទារក គ្រោះថ្នាក់កើតពីជំងឺផ្សេងៗ (ដូចជា សុខភាពមាតា និងកុមារ ទឹកស្អាត អនាម័យ បញ្ហាយុវវ័យ សុខភាពបន្តពូជ...) ។

**យេនឌ័រ ៖** គួរសរសេរពីការទទួលយកសេវា ការចូលរួមចំណែករបស់ស្ត្រីក្នុងការសម្រេចចិត្តនានា និងសកម្មភាពសង្គម និងការលំបាកដែលស្ត្រីកំពុងជួបប្រទះ (បុរសពុំបានជួប) ឬកត្តាទាំងឡាយក្នុងសង្គមដែលនាំឱ្យស្ត្រីជួបការលំបាកញឹកញាប់ជាងបុរស ។

**ភាពក្រីក្រ ៖** សរសេរពីកម្រិតភាពក្រីក្ររបស់ប្រជាជនក្នុងរាជធានី ខេត្ត ដោយបង្ហាញពីបណ្តាមូលហេតុចម្បងៗដែលនាំឱ្យមានគ្រួសារមួយចំនួនធ្លាក់ខ្លួនក្រ មូលហេតុដែលគ្រួសារក្រីក្រមិនអាចកែលម្អជីវភាពរបស់ពួកគេបាន និងមូលហេតុដែលគ្រួសារក្រីក្របានកែលម្អជីវភាពខ្លួន ។

**សាសនា ៖** គួររៀបរាប់ប្រភេទ សាសនា និងចំនួនភាគរយប្រជាពលរដ្ឋដែលកាន់សាសនានីមួយៗក្នុងរាជធានី ខេត្ត។

**អន្តោប្រវេសន៍ និងបំលាស់ទី ៖** ត្រូវសរសេររៀបរាប់អំពីស្ថានភាពនៃការបំលាស់ទីរបស់ប្រជាពលរដ្ឋពីខេត្តនានាចូលមករាជធានីភ្នំពេញ ដើម្បីប្រកបមុខរបរផ្សេងៗដូចជាប្រកបមុខរបរជាកម្មករ រត់ម៉ូតូឌុប កម្មករ

រោងចក្រ និងជនបរទេសដែលចូលមករាជធានី ខេត្ត ជាអ្នកទេសចរ ឬមកប្រកបមុខរបរផ្សេងៗ។ ដូច្នេះ ចំណុចនេះ ត្រូវសរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗដែលពាក់ព័ន្ធនឹងស្ថានភាពទាំងនេះ។

ក្រៅពីស្ថានភាពសំខាន់ៗខាងលើរាជធានី ខេត្តអាចធ្វើការរៀបរាប់បន្ថែមអំពីស្ថានភាពផ្សេងទៀតដែលពាក់ព័ន្ធនឹងស្ថានភាពសង្គមកិច្ចផ្អែកតាមស្ថានភាពជាក់ស្តែងរបស់រាជធានីខេត្ត ដូចជាការលើកកម្ពស់សិទ្ធិកុមារ និងប្រជាពលរដ្ឋទូទៅការទប់ស្កាត់សកម្មភាពជួញដូរស្ត្រីនិងកុមារការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងការជួយជនចាស់ជរាគ្មានទីពឹង និវត្តន៍ជន កុមារកំព្រា ជនអនាថា។ល។

### ១.២.៣. ស្ថានភាពនៃការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

ផ្នែកនេះត្រូវសរសេររៀបរាប់អំពីអ្វីខ្លះដែលជាភាពខ្លាំង (សក្តានុពល) និងផលប្រយោជន៍ដែលរាជធានីខេត្តមានដូចជាដីធ្លី និងធនធានធម្មជាតិ និងអ្វីខ្លះដែលជាបញ្ហាប្រឈម ឬឧបសគ្គដែលកំពុងគំរាមកំហែងដល់ដីធ្លី ធនធានធម្មជាតិ និងបរិស្ថាន ។ ផ្នែកនេះក៏ត្រូវសរសេររៀបរាប់អំពីគ្រោះថ្នាក់ ការបាត់បង់ខូចខាត ការបំផ្លិចបំផ្លាញ ការប្រែប្រួល និង ផលប៉ះពាល់ជាអវិជ្ជមានទាំងឡាយដែលកើតមានឡើងនៅក្នុងរាជធានីខេត្ត ដោយមនុស្សជាអ្នកបង្កឡើង ឬ ដោយធម្មជាតិ ។ ការសរសេរផ្នែកនេះត្រូវផ្អែកលើលទ្ធផលនៃការវិភាគការប្រើប្រាស់ ដីធ្លី ការវិភាគធនធានធម្មជាតិ ការវិភាគបរិស្ថាន ការវិភាគគ្រោះមហន្តរាយ និងការវិភាគបរិស្ថានដោយផ្តោតលើ ៖

**ការប្រើប្រាស់ដីធ្លី ៖** ប្រភេទសំខាន់ៗនៃការប្រើប្រាស់ដីធ្លី (ដីលំនៅដ្ឋាន ដីធ្វើស្រែ ដីចំការ ដីសម្រាប់ការវិនិយោគដីសម្បទាន តំបន់អភិរក្ស ជាដើម) និងបញ្ហាប្រឈមសំខាន់ៗដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លីនេះ។ ជាពិសេសចំពោះការប្រើប្រាស់ដីធ្លីសម្រាប់លំនៅដ្ឋាន ត្រូវរៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការកំណត់ប្រភេទលំនៅដ្ឋាន ការផ្លាស់ប្តូរទីតាំង ការរៀបចំនិងគ្រប់គ្រង សំណង់អាណាធិបតេយ្យ និងការរៀបចំប្លង់លំនៅដ្ឋានជាដើម។ល។

**ធនធានធម្មជាតិ ៖** (ដីធ្លី ព្រៃឈើ សត្វព្រៃ ធនធានជលផល បឹង អូរ ស្ទឹង រ៉ែ...។ល។) សំខាន់ៗ ដែលប្រជាជនពឹងផ្អែកលើធនធានទាំងនេះ សម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់។ ដូច្នេះ ត្រូវសរសេរពីកម្រិតនៃការប្រើប្រាស់ធនធានទាំងនេះ និងបញ្ហាប្រឈមសំខាន់ៗដែលកំពុងជួបប្រទះពាក់ព័ន្ធនឹងការប្រើប្រាស់នេះ។

**បរិស្ថាន ៖** ចំណុចនេះ ត្រូវរៀបរាប់អំពីសក្តានុពលរបស់រាជធានី ខេត្តពាក់ព័ន្ធនឹងបរិស្ថាន ដូចជាកន្លែងលំហាត់ប្រាណ និងសួនឧទ្យានសាធារណៈ ទីលានចាក់សំរាម និងបញ្ហានានាដែលគំរាមកំហែងលើ បរិស្ថានដូចជាការបំពុលបរិយាកាស កាកសំណល់រឹងនិងរាវ ។ល។

**គ្រោះមហន្តរាយសំខាន់ៗ ៖** ការបំផ្លិចបំផ្លាញដោយសារខ្យល់ព្យុះ ភ្លើងឆេះផ្ទះ គ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះ គ្រោះទឹកជំនន់ជាដើម ។

**ការប្រែប្រួលអាកាសធាតុ៖** ទឹកជំនន់ ភាពរាំងស្ងួត សីតុណ្ហភាពឡើងខ្ពស់ កម្រិតទឹកភ្លៀងមិនទៀងទាត់។

**១.២.៤. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

ផ្នែកនេះត្រូវសរសេររៀបរាប់ដោយសង្ខេបអំពីចំណុចសំខាន់ៗមួយចំនួនដូចជា អភិបាលកិច្ច ការគ្រប់គ្រងដែនដី ស្ថិតិប្រជាជន កិច្ចការសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដោយផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាពរដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ។ ទិន្នន័យ និងព័ត៌មានមួយចំនួនដែលត្រូវរៀបរាប់ក្នុងផ្នែកនេះ មានបង្ហាញនៅក្នុងតារាងអំពីព័ត៌មានសំខាន់ៗដូចជា ផ្ទៃដីរាជធានី ខេត្ត ចំនួនក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ និងស្ថិតិប្រជាជន ។

**អភិបាលកិច្ច៖** រៀបរាប់ពីភាពខ្លាំង និងបញ្ហាប្រឈមពាក់ព័ន្ធនឹងអភិបាលកិច្ចនៅរាជធានី ខេត្ត

**ការគ្រប់គ្រងដែនដី ៖** រៀបរាប់ពីភាពខ្លាំង និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការរៀបចំ និងគ្រប់គ្រងដែនដីរដ្ឋបាល ដូចជា ការកំណត់ព្រំប្រទល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ និង តំបន់សំខាន់ៗក្នុងរាជធានី ខេត្ត ការបង្កើតភូមិថ្មី ការរៀបចំប្លង់គោលជាដើម។

**ការគ្រប់គ្រងស្ថិតិ៖** រៀបរាប់ពីបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការចុះបញ្ជី និងការងារអត្រានុកូលដ្ឋាន

**ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖** រៀបរាប់ពីភាពខ្លាំង និងបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រង និងការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ និងតំបន់ទីប្រជុំជនសំខាន់ៗ ផ្សេងទៀត ។

**ចំពោះខេត្តជាប់ព្រំដែន គួរបញ្ចូលការងារព្រំដែន ៖** ភាពងាយស្រួល និងការលំបាកក្នុងការរៀបចំ និងគ្រប់គ្រងច្រកព្រំដែន និងកិច្ចសហការជាមួយប្រទេសជិតខាង។

## ជំពូកទី២ ក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត

នេះជាជំពូកសំខាន់នៃផែនការអភិវឌ្ឍន៍រាជធានី ខេត្តដែលត្រូវសរសេរដោយផ្អែកលើការពិចារណា និងឱ្យតម្លៃសមស្រប មានភាពគ្រប់ជ្រុងជ្រោយ ផ្អែកលើសក្ដានុពល ឧបសគ្គ ឬបញ្ហាប្រឈមដែលបានរកឃើញនៅក្នុងការវិភាគស្ថានភាពរាជធានី ខេត្តក្នុងជំពូកទី១ ។

ផ្នែកនេះ ត្រូវសរសេរដោយផ្អែកលើតារាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត ដែលក្រុមប្រឹក្សាបានអនុម័តរួចនៅក្នុងជំហានទី២ សកម្មភាព ២.២។

### ២.១. ចក្ខុវិស័យអភិវឌ្ឍន៍

ចក្ខុវិស័យអភិវឌ្ឍន៍គឺជាអ្វីដែលក្រុមប្រឹក្សារាជធានីខេត្តចង់សម្រេចបានជាចម្បងក្នុងការអភិវឌ្ឍន៍រាជធានីខេត្ត។

ការសរសេរអំពីចក្ខុវិស័យមិនត្រូវមានមហិច្ឆតាខ្ពស់ហួសពីសមត្ថភាព លទ្ធភាពដែលនាំឱ្យអនុវត្តមិនបាន ប៉ុន្តែក៏មិនគួរសរសេរដែលមានលក្ខណៈងាយអនុវត្តពេក នាំឱ្យបាត់ភាពខិតខំប្រឹងប្រែង ខ្ជះខ្ជាយពេលវេលា និងធនធាននានានៅពេលអនុវត្ត។ ក្នុងចក្ខុវិស័យអភិវឌ្ឍន៍ត្រូវមានខ្លឹមសារចង់បានការកែលម្អស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច អភិបាលកិច្ច ផ្អែកតាមតម្រូវការអភិវឌ្ឍន៍ជាក់ស្ដែងរបស់រាជធានី ខេត្តនីមួយៗ ។

ការសរសេរចក្ខុវិស័យអភិវឌ្ឍន៍ត្រូវផ្អែកលើក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្តដែលបានរៀបចំក្នុងជំហានទី២ ដំណើរការកសាងសេចក្ដីព្រាងផែនការអភិវឌ្ឍន៍។

### ២.២. គោលបំណងអភិវឌ្ឍន៍

គោលបំណងអភិវឌ្ឍន៍ គឺជាការបរិយាយពីលទ្ធផលរួមដែលក្រុមប្រឹក្សារាជធានី ខេត្ត រំពឹងថានឹងសម្រេចឱ្យបានតាមរយៈការអនុវត្តផែនការអភិវឌ្ឍន៍របស់រាជធានីខេត្ត ដែលរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យអភិវឌ្ឍន៍របស់រាជធានី ខេត្ត។

ការសរសេរគោលបំណងអភិវឌ្ឍន៍ ត្រូវយោងតាមខ្លឹមសាររបស់ចក្ខុវិស័យអភិវឌ្ឍន៍ដែលបានសរសេរក្នុងចំណុច ២.១ខាងលើ ។ ក្រុមប្រឹក្សារាជធានី ខេត្តគួរកំណត់យកគោលដៅអភិវឌ្ឍន៍មូលដ្ឋានខ្លួនឱ្យបានសមស្របដោយថ្លឹងថ្លែងពីតុល្យភាពរវាងទំហំនៃគោលបំណងដែលបានកំណត់។គោលបំណងគួរសរសេរតាមផ្នែកទាំងបួន (ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកប្រើប្រាស់ដីធ្លី និងគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ និងផ្នែករដ្ឋបាល និងសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ)។ ការសរសេរអំពីគោលបំណងអភិវឌ្ឍន៍នេះ ក៏ត្រូវធ្វើការថ្លឹងថ្លែងជាមួយនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងគោលនយោបាយជាតិផងដែរ ។

### ២.៣. គោលដៅអភិវឌ្ឍន៍

គោលដៅអភិវឌ្ឍន៍ គឺជាការបរិយាយអំពីលទ្ធផលនានាដែលក្រុមប្រឹក្សារាជធានីរំពឹងថានឹងសម្រេចបានតាមវិស័យនីមួយៗ តាមរយៈការអនុវត្តផែនការអភិវឌ្ឍន៍របស់រាជធានី ខេត្ត ដែលរួមចំណែកក្នុងការសម្រេចបាននូវគោលបំណងអភិវឌ្ឍន៍របស់រាជធានី ខេត្ត ។

គោលដៅអភិវឌ្ឍន៍ត្រូវមានលក្ខណៈជាក់លាក់ដែលអាចវាស់វែងបាន អាចសម្រេចបានក្នុងរយៈពេលកំណត់មួយ និងឆ្លើយតបទៅគោលបំណងអភិវឌ្ឍន៍។ គោលដៅអភិវឌ្ឍន៍ត្រូវសរសេរតាមវិស័យនីមួយៗ ក្នុងផ្នែកទាំងបួន។ គោលដៅនីមួយៗត្រូវមានការកំណត់សូចនាករឱ្យបានជាក់លាក់ ដោយផ្អែកលើសូចនាករនៃកម្រងឯកសារព័ត៌មានរាជធានី ខេត្ត និងត្រូវធ្វើការថ្លឹងថ្លែងជាមួយនឹងគោលបំណងអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាផងដែរ។

## ២.៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍

### ២.៤.១. យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច

ការអភិវឌ្ឍន៍សេដ្ឋកិច្ច គឺជាបង្គោលគ្រឹះមួយក្នុងចំណោមបង្គោលគ្រឹះនានានៃការអភិវឌ្ឍន៍សង្គម។ ដូច្នេះ ក្នុងចំណុចនេះ ត្រូវបរិយាយពីបណ្តាវិស័យស្នូលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់រាជធានី ខេត្ត ដោយត្រូវយកចិត្តទុកដាក់ពិចារណាពីលទ្ធភាពកម្រិតនិរន្តរភាពនៃសក្តានុពលសេដ្ឋកិច្ចរបស់វិស័យពាក់ព័ន្ធក្នុងការអភិវឌ្ឍរាជធានី ខេត្ត។

### ២.៤.២. យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច

ការអភិវឌ្ឍសង្គមកិច្ច ក៏ជាបង្គោលគ្រឹះមួយដ៏សំខាន់ក្នុងចំណោមបង្គោលគ្រឹះនានានៃការអភិវឌ្ឍសង្គម។ ក្នុងចំណុចនេះ ត្រូវបរិយាយពីបណ្តាការងារសង្គមកិច្ចដែលចង់បាន ដើម្បីរួមចំណែកក្នុងដំណើរការអភិវឌ្ឍមូលដ្ឋាន។ ការសរសេរនេះត្រូវបរិយាយអំពីផ្នែករឹង(ផ្នែករូបវន្ត) និងផ្នែកទន់(ផ្នែកអរូបវន្ត)ទាំងចំពោះមុខ និងនិន្នាការតទៅថ្ងៃមុខ។

### ២.៤.៣. យុទ្ធសាស្ត្រប្រើប្រាស់ដីធ្លី និងគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

ដីធ្លី ធនធានធម្មជាតិ និងបរិស្ថាន ជាកត្តាពុំអាចខ្វះបានក្នុងសកម្មភាពអភិវឌ្ឍន៍។និរន្តរភាពក្នុងការអភិវឌ្ឍ គឺអាស្រ័យទៅនឹងភាពគង់វង្សនៃសក្តានុពល ការប្រើប្រាស់ និងការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ និងបរិស្ថាន និងសមត្ថភាពរបស់មនុស្ស។ដូច្នេះក្នុងចំណុចនេះត្រូវបរិយាយអំពីការគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ធនធានធម្មជាតិ និងបរិស្ថាន ផ្អែកលើស្ថានភាពដែលបានលើកឡើងក្នុងជំពូកទី១។

ក្នុងយុទ្ធសាស្ត្រប្រើប្រាស់ដីធ្លី ការគ្រប់គ្រង ធនធានធម្មជាតិ និងបរិស្ថានត្រូវធ្វើការរៀបរាប់ដូចជាតំបន់(ដី) ដែលត្រូវប្រើប្រាស់សម្រាប់លំនៅដ្ឋាន ដីសម្រាប់រៀបចំតំបន់អភិវឌ្ឍន៍ ដីសម្រាប់គ្រប់គ្រងប្រើប្រាស់ដោយសហគមន៍នានា មូលដ្ឋានគតិយុត្តិដែលកំណត់តំបន់ សម្រាប់ផ្លាស់ប្តូរគោលបំណងប្រើប្រាស់ការអភិរក្ស និងភ្ជាប់ជាមួយនូវផែនទីប្រើប្រាស់ដីធ្លី(បើមាន)។ ជាមួយនេះ ត្រូវសរសេរពីតួនាទី និងការទទួលខុសត្រូវរបស់អង្គភាពពាក់ព័ន្ធក្នុងការគ្រប់គ្រងប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានក្នុងរាជធានី ខេត្ត។

ផ្អែកលើស្ថានភាពគ្រោះមហន្តរាយ និងប្រែប្រួលអាកាសធាតុដែលបានរៀបរាប់នៅក្នុងជំពូកទី១ ត្រូវបរិយាយអំពីយុទ្ធសាស្ត្រសំខាន់ៗសម្រាប់គ្រប់គ្រង និងកាត់បន្ថយគ្រោះភ័យ គ្រោះថ្នាក់ ការបំផ្លិចបំផ្លាញនានា បណ្តាលមកពីគ្រោះមហន្តរាយ និងការផ្លាស់ប្តូរ ឬឥទ្ធិពលជាអវិជ្ជមានដែលបាន និងឬអាចកើតមានឡើង ដោយធម្មជាតិ និងឬដោយការធ្វេសប្រហែសរបស់មនុស្ស។ ជាមួយនេះដែរ ត្រូវសរសេរពីតួនាទី និងការទទួលខុសត្រូវរបស់អង្គភាពពាក់ព័ន្ធក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ និងការសម្របសម្រួលជាមួយនឹងការប្រែប្រួលអាកាសធាតុនៅក្នុងរាជធានី ខេត្ត និងធនធានដែលត្រូវការសម្រាប់ត្រៀមបង្ការ និងកាត់បន្ថយគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនានា ។

**២.៤.៤. យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

ផ្អែកលើស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈដែលបានរៀបរាប់នៅក្នុងជំពូកទី១ ផ្នែកនេះត្រូវបរិយាយអំពីយុទ្ធសាស្ត្រសំខាន់ៗសម្រាប់ការគ្រប់គ្រងដែនដីរដ្ឋបាល ដូចជាការកំណត់ព្រំប្រទល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិឱ្យបានច្បាស់លាស់ ការពង្រឹងការគ្រប់គ្រង និងថែរក្សាប្រព័ន្ធទិន្នន័យ និងព័ត៌មានអំពីស្ថិតិប្រជាជន និងព័ត៌មានចាំបាច់ផ្សេងទៀត វិធានការលើកកម្ពស់សន្តិសុខ ការអភិវឌ្ឍ និងការថែរក្សាទេសភាព បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈក្នុងរាជធានី ខេត្ត។

## ២.៥. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

ផ្អែកតាមទំហំនៃសូចនាករអភិវឌ្ឍន៍ដែលបានសរសេរខាងលើ ត្រូវធ្វើការគណនាប៉ាន់ស្មានអំពីតម្រូវការថវិកាចំណាយ។ ថវិកាចំណាយមានពីរផ្នែក គឺផ្នែកចំណាយចរន្ត និងផ្នែកចំណាយមូលធន។ ទោះបីជាថវិកាចំណាយនេះមិនទាន់មានលក្ខណៈត្រឹមត្រូវឥតខ្ចោះក៏ដោយ ក៏ថវិកាចំណាយនេះបង្ហាញឱ្យឃើញពីភាពម្ចាស់ការក្នុងកម្រិតណាមួយរបស់រាជធានី ខេត្ត នៅពេលបំប្លែងសូចនាករអភិវឌ្ឍន៍៥ឆ្នាំទៅជាទំហំនៃគម្រោងការងារ ឬសកម្មភាពអភិវឌ្ឍន៍ប្រចាំឆ្នាំ។ សេចក្តីណែនាំលម្អិតសម្រាប់រៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនឹងធ្វើការណែនាំជាក្រោយ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៣ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និងសមិទ្ធផលនៃការងារនានាជាកិច្ចការចាំបាច់ និងមានសារៈសំខាន់ពុំអាចរំលងបានសម្រាប់ការងារគ្រប់គ្រងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត។ ការតាមដាន គឺត្រូវធ្វើឡើងដើម្បីជំរុញឱ្យការងារអនុវត្តបានប្រព្រឹត្តទៅដល់គោលដៅអភិវឌ្ឍន៍ដែលបានកំណត់ ហើយក៏ដើម្បីមានការសម្រេចចិត្ត (ផ្តល់ការលើកទឹកចិត្ត ឬកែតម្រូវជាចាំបាច់) ត្រង់ប្រការណាមួយដែលមិនសមស្រប។ ដូច្នេះ ក្នុងការសរសេរអំពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ត្រូវរៀបរាប់អំពីផែនការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ យន្តការ ប្រតិបត្តិករ វិធីសាស្ត្រធ្វើការតាមដានត្រួតពិនិត្យ និងវាយតម្លៃ សូចនាករគោលបំណងសូចនាករដើមគ្រា និងពេលវេលាសម្រាប់ប្រតិបត្តិការការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ។

ផ្នែកនេះ ត្រូវសរសេរដោយផ្អែកតាមក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដូចមានរៀបរាប់ក្នុងជំហានទី២ សកម្មភាព ២.៤។

### ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ គឺជាបណ្តាឯកសារយោងសម្រាប់បង្កើនទម្ងន់នៃចំណុចពាក់ព័ន្ធណាមួយ។ហេតុនេះការបញ្ចូលឯកសារឧបសម្ព័ន្ធក្នុងសៀវភៅផែនការអភិវឌ្ឍន៍ គឺជាការសម្រេចចិត្តរបស់រាជធានី ខេត្ត។

ឯកសារដែលអាចបញ្ចូលជាឧបសម្ព័ន្ធរួមមាន ៖

- គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាអំពីការកសាងផែនការ
- រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត
- លទ្ធផលសំខាន់ៗនៃការវិភាគស្ថានភាពរាជធានី ខេត្ត
- លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការកសាងផែនការ
- ផែនទីសំខាន់ៗ ដូចជាផែនទីនៃការប្រើប្រាស់ដីធ្លី ផែនទីតំបន់ទេសចរណ៍។ល។

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធ១៖ បញ្ជីតារាង**

**ឧបសម្ព័ន្ធ២៖ ទំនាក់ទំនងរវាងដើមឈើបញ្ហា និងដើមឈើដំណោះស្រាយ**

## ឧបសម្ព័ន្ធ ១៖ បញ្ជីតារាង

**តារាង ១.១៖ ទម្រង់គំរូប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

| ល.រ | សកម្មភាព | ពេលវេលា | ទីកន្លែង | អ្នកទទួលខុសត្រូវ | ថវិកា | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ប្រតិទិនាការងារកសាងផែនការអភិវឌ្ឍន៍ខាងលើនេះ ត្រូវបានក្រុមប្រឹក្សារាជធានី ខេត្ត.........អនុម័តក្នុងកិច្ចប្រជុំ......លើកទី....នាថ្ងៃទី....ខែ.........ឆ្នាំ...។

ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត

## តារាង ១.២៖ តារាងវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ

អង្គភាពស្នើ៖_______________ កាលបរិច្ឆេទ៖_______________

| បញ្ហា | មូលហេតុ | តម្រូវការយេនឌ័រ |
|---|---|---|
| ផ្នែកសេដ្ឋកិច្ច | | |
| | | |
| | | |
| ផ្នែកសង្គមកិច្ច | | |
| | | |
| | | |
| ផ្នែកការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ | | |
| | | |
| | | |
| ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | |
| | | |
| | | |

## តារាង ១.៣៖ តារាងបូកសរុបការវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ

កាលបរិច្ឆេទ៖_______________

| បញ្ហា | មូលហេតុ | តម្រូវការយេនឌ័រ |
|---|---|---|
| ផ្នែកសេដ្ឋកិច្ច | | |
| | | |
| | | |
| ផ្នែកសង្គមកិច្ច | | |
| | | |
| | | |
| ផ្នែកការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ | | |
| | | |
| | | |
| ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | |
| | | |
| | | |

## តារាង ២.១÷ តារាងវិភាគស្ថានភាពរាជធានី ខេត្តដែលបានចាត់អាទិភាព

កាលបរិច្ឆេទ៖_______________

| បញ្ហា | មូលហេតុ | តម្រូវការយេនឌ័រ |
|---|---|---|
| ផ្នែកសេដ្ឋកិច្ច | | |
| | | |
| | | |
| ផ្នែកសង្គមកិច្ច | | |
| | | |
| | | |
| ផ្នែកការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ | | |
| | | |
| | | |
| ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | |
| | | |
| | | |

# តារាង ២.២៖ តារាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត

| ចក្ខុវិស័យ៖ | | | | | | | |
|---|---|---|---|---|---|---|---|
| **១. ផ្នែកសេដ្ឋកិច្ច** | | | | | | | |
| គោលបំណង&គោលដៅ | ដំណោះស្រាយ | សូចនាករ | | | | អង្គភាពទទួលខុសត្រូវ | ប្រភពទិន្នន័យ |
| | | បរិយាយសង្ខេប | ឯកតា | ២០១៨ (បច្ចុប្បន្ន) | ២០១៩ (គោលដៅ) | | |
| គោលបំណងអភិវឌ្ឍន៍សេដ្ឋកិច្ច៖ | | | | | | | |
| យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច៖ | | | | | | | |
| ១.១ គោលបំណង<br>១.១.១ គោលដៅ<br><br><br>១.១.២ គោលដៅ | ១.១.១.១ ដំណោះស្រាយ<br>១.១.១.២ ដំណោះស្រាយ<br><br>១.១.២.១ ដំណោះស្រាយ<br>១.១.២.២ ដំណោះស្រាយ | | | | | | |
| ១.២. គោលបំណង<br>១.២.១ គោលដៅ<br><br><br>១.២.២ គោលដៅ | ១.២.១.១ ដំណោះស្រាយ<br>១.២.១.២ ដំណោះស្រាយ<br><br>១.២.២.១ ដំណោះស្រាយ<br>១.២.២.២ ដំណោះស្រាយ | | | | | | |

| ២. ផ្នែកសង្គមកិច្ច | | | | | | | |
|---|---|---|---|---|---|---|---|
| គោលបំណង & គោលដៅ | ដំណោះស្រាយ | សូចនាករ | | | | អង្គភាពទទួលខុសត្រូវ | ប្រភពទិន្នន័យ |
| | | បរិយាយសង្ខេប | ឯកតា | ២០១៨<br>(បច្ចុប្បន្ន) | ២០១៩<br>(គោលដៅ) | | |
| គោលបំណងអភិវឌ្ឍន៍សង្គមកិច្ចៈ | | | | | | | |
| យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ចៈ | | | | | | | |
| ២.១. គោលបំណង<br>២.១.១ គោលដៅ<br><br>២.១.២ គោលដៅ | <br>២.១.១.១ ដំណោះស្រាយ<br>២.១.១.២ ដំណោះស្រាយ<br><br>២.១.២.១ ដំណោះស្រាយ<br>២.១.២.២ ដំណោះស្រាយ | | | | | | |
| ២.២. គោលបំណង<br>២.២.១ គោលដៅ<br><br>២.២.២ គោលដៅ | <br>២.២.១.១ ដំណោះស្រាយ<br>២.២.១.២ ដំណោះស្រាយ<br><br>២.២.២.១ ដំណោះស្រាយ<br>២.២.២.២ ដំណោះស្រាយ | | | | | | |

| ៣. ផែនការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ | | | | | | | |
|---|---|---|---|---|---|---|---|
| គោលបំណង & គោលដៅ | ដំណោះស្រាយ | សូចនាករ | | | | អង្គភាពទទួលខុសត្រូវ | ប្រភពទិន្នន័យ |
| | | បរិយាយសង្ខេប | ឯកតា | ២០១៤ (បច្ចុប្បន្ន) | ២០១៩ (គោលដៅ) | | |
| គោលបំណងប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ | | | | | | | |
| យុទ្ធសាស្ត្រប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ | | | | | | | |
| ៣.១. គោលបំណង<br>៣.១.១ គោលដៅ<br><br>៣.១.២ គោលដៅ | ៣.១.១.១ ដំណោះស្រាយ<br>៣.១.១.២ ដំណោះស្រាយ<br>៣.១.២.១ ដំណោះស្រាយ<br>៣.១.២.២ ដំណោះស្រាយ | | | | | | |
| ៣.២. គោលបំណង<br>៣.២.១ គោលដៅ<br><br>៣.២.២ គោលដៅ | ៣.២.១.១ ដំណោះស្រាយ<br>៣.២.១.២ ដំណោះស្រាយ<br>៣.២.២.១ ដំណោះស្រាយ<br>៣.២.២.២ ដំណោះស្រាយ | | | | | | |

| ៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | |
|---|---|---|---|---|---|---|---|
| គោលបំណង & គោលដៅ | ដំណោះស្រាយ | សូចនាករ | | | | អង្គភាពទទួលខុសត្រូវ | ប្រភពទិន្នន័យ |
| | | បរិយាយសង្ខេប | ឯកតា | ២០១៤ (បច្ចុប្បន្ន) | ២០១៩ (គោលដៅ) | | |
| គោលបំណងគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ៖ | | | | | | | |
| យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ៖ | | | | | | | |
| ៥.១. គោលបំណង<br>៥.១.១ គោលដៅ<br><br><br>៥.១.២ គោលដៅ | <br>៥.១.១.១ ដំណោះស្រាយ<br>៥.១.១.២ ដំណោះស្រាយ<br><br>៥.១.២.១ ដំណោះស្រាយ<br>៥.១.២.២ ដំណោះស្រាយ | | | | | | |
| ៥.២. គោលបំណង<br>៥.២.១ គោលដៅ<br><br><br>៥.២.២ គោលដៅ | <br>៥.២.១.១ ដំណោះស្រាយ<br>៥.២.១.២ ដំណោះស្រាយ<br><br>៥.២.២.១ ដំណោះស្រាយ<br>៥.២.២.២ ដំណោះស្រាយ | | | | | | |

## តារាង ២.៣៖ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

| ១. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| គោលបំណង & គោលដៅ | ដំណោះស្រាយ | សូចនាករ | | | | | | | | | អង្គភាពទទួលខុសត្រូវ | ប្រភពទិន្នន័យ |
| | | បរិយាយសង្ខេប | ឯកតា | ២០១៤ (បច្ចុប្បន្ន) | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៩ (គោលដៅ) | | |
| ១.១. គោលបំណង | | | | | | | | | | | | |
| ១.១.១ គោលដៅ | ១.១.១.១ ដំណោះស្រាយ<br>១.១.១.២ ដំណោះស្រាយ | | | | | | | | | | | |
| ១.១.២ គោលដៅ | ១.១.២.១ ដំណោះស្រាយ<br>១.១.២.២ ដំណោះស្រាយ | | | | | | | | | | | |
| ១.២. គោលបំណង | | | | | | | | | | | | |
| ១.២.១ គោលដៅ | ១.២.១.១ ដំណោះស្រាយ<br>១.២.១.២ ដំណោះស្រាយ | | | | | | | | | | | |
| ១.២.២ គោលដៅ | ១.២.២.១ ដំណោះស្រាយ<br>១.២.២.២ ដំណោះស្រាយ | | | | | | | | | | | |

| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| គោលបំណង & គោលដៅ | ដំណោះស្រាយ | សូចនាករ | | | | | | | | | អង្គភាពទទួលខុសត្រូវ | ប្រភពទិន្នន័យ |
| | | បរិយាយសង្ខេប | ឯកតា | ២០១៤ (បច្ចុប្បន្ន) | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៩ (គោលដៅ) | | |
| ២.១. គោលបំណង | | | | | | | | | | | | |
| ២.២. គោលបំណង | | | | | | | | | | | | |

| ៣. ផ្នែកការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| គោលបំណង & គោលដៅ | ដំណោះស្រាយ | សូចនាករ | | | | | | | | | អង្គភាពទទួលខុសត្រូវ | ប្រភពទិន្នន័យ |
| | | បរិយាយសង្ខេប | ឯកតា | ២០១៤ (បច្ចុប្បន្ន) | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៩ (គោលដៅ) | | |
| ១. គោលបំណង | | | | | | | | | | | | |
| ២. គោលបំណង | | | | | | | | | | | | |

## ៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

| គោលបំណង & គោលដៅ | ដំណោះស្រាយ | សូចនាករ | | | | | | | | | អង្គភាពទទួលខុសត្រូវ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បរិយាយសង្ខេប | ឯកតា | ២០១៤ (បច្ចុប្បន្ន) | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៩ (គោលដៅ) | | |
| ៥.១. គោលបំណង | | | | | | | | | | | | |
| ៥.២. គោលបំណង | | | | | | | | | | | | |

## ឧបសម្ព័ន្ធ ២÷ ទំនាក់ទំនងរវាងដើមឈើបញ្ហា និងដើមឈើដំណោះស្រាយ

